# វគ្គទី ៥

# បានជួបប៉ាណាស៎



ម៉េង សាវ៉ាន់ និងពូជិម វិលត្រឡប់ទៅដល់ឃ្លាំងឯពេទ្យលោកសង្ឃវិញ ក៏ជួបពូឈុំឈរចាំនៅមាត់ទ្វារឃ្លាំង ។

-នែ៎ ! ពួកឯងមកបើកលុយអោយហើយទៅ ! ខ្ញុំចាំមួយព្រឹកទៅហើយ(ពូឈុំនិយាយទៅកាន់សាវ៉ាន់និងម៉េង ) ស្អែកថ្ងៃភ្ជុំបិណ្ឌចៅកែគាត់បើកប្រាក់ខែអោយមុន ១ខែ និងរង្វាន់សំរាប់ថ្ងៃបុណ្យភ្ជុំផងណា៎ !។ ហើយម៉េចទៅរឿងក្មេងៗនោះរួចរាល់ហើយឬនៅ ? ។

សាវ៉ាន់ចុះពីលើឡានទៅស៊ីញ៉េទទួលប្រាក់ពីពូឈុំ ឯម៉េងឈរនិយាយរៀបរាប់រឿងរ៉ាវប្រាប់ពូឈុំ ចំណែកពូជិមគ្មានមុខការត្រូវបើកប្រាក់ខែដូចគេ ក៏ធ្វើមុខជូរលាអ្នកទាំងអស់គ្នាបំរុងដើរទៅផ្ទះ តែត្រូវពូឈុំស្រែកឃាត់ថា ៖

-នែ៎ លោកប្អូនជិមអើយ ស្អែកថ្ងៃបុណ្យភ្ជុំគិតនាំយាយទៅភ្ជុំនៅវត្តណា ? ខ្ញុំចង់បបួលលោកប្អូនទៅវត្តក្បៀនស្វាយនិងទៅលេងផ្ទះខ្ញុំម្តងយ៉ាងម៉េចដែរ ?

-បាទលោកបង ! ស្រុកខ្ញុំនៅគគីជិតគ្នាស្រាប់មានរឿងអីដែលខ្ញុំប្រកែកមិនទៅក្បៀនស្វាយ ? បានលោកបងបបួលស្រួលហើយ ព្រោះលោកបងមានយានជំនិះស្រាប់បានទៅក្បៀនស្វាយក៏ដូចជាទៅស្រុកខ្ញុំដែរ !(ពូជិមត្រេកអរណាស់ បានពូឈុំរាប់អាននាំគាត់ទៅលេងផ្ទះក្បៀនស្វាយ)។

នាយសាវ៉ាន់កាន់ប្រាក់ខែមួយបាច់សើចញញឹមញញែមពោលឡើងថា ៖

-លោកមា ! ស្អែកនេះខ្ញុំលឺថាបងម៉េងគាត់ទៅវត្តនៅក្បៀនស្វាយដែរ ស្រួលហើយគាត់មានឡានស្រាប់ អាចដឹកពួកយើងទៅធ្វើទេសចរទីនេះទីនោះបានតាមការគួរមែនទេបងម៉េង ? ( សាវ៉ាន់ពោលហើយសម្លឹងមុខម៉េង )

-កុំអាលសង្ឃឹមឡានខ្ញុំពេកលាវ៉ាន់អើយ ! ដឹងស្រាប់ហើយថ្ងៃបុណ្យអីចឹងគ្រាន់តែកូនខ្ញុំ អាមុី, អាមុីង, អាមុីល, អាមុំ, អាម៉ានិងពួកម៉ាកវាពេញមួយឡានទៅហើយ និងមិនគិតអាកូនភ្លោះខ្ញុំពីរដែលម៉ែវាបីនៅដៃផងទេ !ហើយបើលោសាវ៉ាន់ឯងខ្ចីឡានខ្ញុំដឹកសង្សារ ឬក៏ចង់ទៅកន្លែងស្ងាត់សង់ទីម៉ង់អីពីរនាក់អត់កើតទេ ! ព្រោះកងទ័ពខ្ញុំនោះរញីរញៃខ្លាំងណាស់ ! ។

-មិនអីទេបងម៉េង ! បងឯងនាំប្រពន្ធនឹងកូនបងទាំងអស់ទៅផងចុះ ! ខ្ញុំចូលចិត្តក្មេងៗណាស់ ថ្ងៃបុណ្យភ្ជុំអីចឹង ទាំងចាស់ទាំងក្មេងសប្បាយធ្វើបុណ្យទាំងអស់គ្នាគ្មានគិតរឿងផ្ទាល់ខ្លួនអីទេ !។

ពេលនោះនាងម៉ាចត្រឡប់មកពីផ្សារដើរកាត់មាត់ទ្វារឈរស្តាប់គេនិយាយគ្នាបន្តិចក៏ចេញវាចារថា ៖

-ម្ល៉េៗលឺតែក្បៀនស្វាយៗ ម្សិលមិញក៏ក្បៀនស្វាយថ្ងៃនេះក៏ក្បៀនស្វាយ ! ស្អែកក៏ក្បៀនស្វាយ ! គេនាំគ្នាទៅក្បៀនស្វាយអស់ចុះខ្ញុំទៅណាវិញទៅ ?

-អើ ! ខ្លាចអើយ ! បើថាចង់ទៅលេងក្បៀនស្វាយជាមួយគេដែរក៏ទៅទៅ ! គ្មានអ្នកណាឃាត់ឯងទេ ! ឯងធ្វើចុងភៅស្រាប់ ទៅដល់ក្បៀនស្វាយក៏នៅតែចុងភៅ



KHMER STORY LOVERS
សម្រាប់អ្នកចូលចិត្តអាន និង គម្រោងសិល្បៈអក្សរសាស្ត្រខ្មែរ

ដដែលគ្មានអ្នកណាគេដណ្ដើមមុខងារឯងទេ ! មិនថាអីចឹងទាំងអស់គ្នា ? (ពួកឈុំ
ពោលឡើង ហើយអ្នកទាំងអស់គ្នាក៏សើចបន្តរៈ ទាំងនាងម៉ាចទាំងសារ៉ាន់បញ្ចេញ
ទឹកមុខរីករាយបញ្ជាក់ថាពួកគេគ្មានការតំគួន ឬ ប្រកាន់គ្នាទៀតឡើយ )។

.................................

ថ្ងៃ ១៥ រោច ខែភទ្របទជាថ្ងៃបុណ្យភ្ជុំបិណ្ឌនាំងពីព្រលឹមម្ល៉េះមនុស្សម្នាចេញ
ដើរព្រោង..សំដៅទៅវត្ត ។នៅតាមផ្លូវភ្នំពេញគៀនស្វាយដែលមានយានយន្តគ្រ
ប្រភេទបើកបរបន្តកន្ទុយគ្នានោះគេឃើញរថយន្តតូយូតាដឹកទំនិញមួយគ្រឿងផ្ទុកពេ
ណែនដោយក្មេងៗ និងមនុស្សចាស់មួយចំនួន ។ នាយម៉េងជាអ្នកបើកបរ ភ្នែកប្រឹ
មើលផ្លូវខាងមុខ ដែលចង្អៀតក្រែងប៉ះយានដទៃទៀត ហើយក៏ឆ្លៀតស្រែកឃាត់កូ
តូចៗរបស់ខ្លួនដែលរពឹសនៅមិនស្ងៀម ព្រោះវាសប្បាយបានដើរលេងជាមួយឪពុ
ម្ដាយវា ។ បន្តិចអាម៉ុងអើតតាមទ្វារឡាន បន្តិចអាម៉ាទាញដែកចង្កឹះលេខរថយ
លេង ។ ឯប្រពន្ធម៉េងកំពុងពរកូនប្រុសពីរនាក់ អាមួយកំពុងបៅដោះ អាមួយទៀ
ដេកលើភ្លៅនៅមិនស្ងៀមចេះតែទាត់ដោល ។ ម៉េងគ្រវីក្បាលនិយាយទៅកាន់កូន
ថា ៖

_កូនអស់នេះ យកវាទៅណាម្ដងៗពិបាកដល់ហើយវារពឹសក្រៃណាស់រពឹស ! ប
អញប្រាប់អោយហើយអ៊ីយ តែរពឹសពេកប្រយ័ត្នប៉ាធ្វើទ្រុងដាក់ពួកឯងក្នុងនោះ ! រ
ណាមកណាប៉ាសុខចិត្តលីទ្រុងនោះទៅជាមួយស្រួលជាង !។

អាម៉ាឆ្លើយតបឪវាផ្ទុយវិញថា ៖

_អេប៉ានេះ ! ទ្រុងគេសំរាប់ដាក់អាទ្យៗ ! កូនម្ដែខ្ញុំតើ ! ប៉ាឯងដាក់ខ្ញុំនិងអារ
ក្នុងហ្នឹងប្រយ័ត្នបាប !ប៉ាឯង !



ប្ដីប្រពន្ធលីកូនថាឬច្នោះហួសចិត្តសើចសម្លឹងមុខគ្នា ។

មិនយូរប៉ុន្មានរថយន្តបានចូលចតដោយសុវត្ថិភាពក្នុងទីវត្ត ។ ម៉េងពរកូនតូចនិង
ដឹកដៃអាម៉ា ឯសារ៉ាន់ក៏ជួយដឹកដៃអាមុំ នឹងពរអាម៉ុលចុះពីឡាន ។ កូនធំៗឯទៀត
របស់ម៉េងនាំពួកម៉ាកវារត់ប្រសេចប្រសាចពេញផ្ទាវត្ត លាយឡំនិងមនុស្សម្នាដែលមក
កកកុញទីនោះ ។

សារ៉ាន់ភ្នែករំពៃរកមើលនាងសូណេត ក្រែងឃើញនៅក្នុងហ្វូងមនុស្សតែនាយ
ពុំបានប្រទះភ្នែកសោះឃើញតែអ្នកភូមិជិតខាង ។

ក្រុមពួឈុំដែលមាននាងម៉ាច ពូជិម មីងសៅនឹងក្រុមគ្រួសារនាយម៉េងសុទ្ធ
តែមានម្ហូបម្ហារៀបចំរួចជាស្រេចឡើងទៅលើសាលាឆាន់រាប់បាត្រជាមួយពុទ្ធបរិស័ទ
ឯទៀត ។ សារ៉ាន់នឹកឆ្ងល់ថាហេតុអ្វីបានជាមិនឃើញម្ដាយខ្លួន និងក្រុមគ្រួសារនាង
សូណេតមកដល់ ? ក៏ចេះតែឈរអើតមើលទៅផ្លូវ ។ ម៉េងឃើញដូច្នោះក៏ដើរទៅកេះ
សារ៉ាន់ហើយពោលថា ៖

_កុំអន្ទះសាពេក ! មកតាមខ្ញុំ ! យើងយកឡានទៅទទួលអ្នកទាំងអស់គ្នានោះ
នៅឯផ្ទះតែម្ដងទៅ !

សារ៉ាន់លឺម៉េងពោលដូច្នោះត្រេកអរណាស់ ក៏ដើរតាមម៉េងសំដៅរថយន្ត ។
ម៉េងនិងសារ៉ាន់ដើរលបៗឡើងឡានប្រញាប់ប្រញាល់ខ្លាចពួកកូនៗវាឃើញវារត់តាម
ជិះឡានទៅដែរ ។

រថយន្តចេញពីវត្តបរមិនឆ្ងាយប៉ុន្មានក៏ទៅដល់ផ្ទះនាងសូណេត ជួនគ្នានិងពេល
នាងបំរុងចាកចេញពីផ្ទះមកវត្តដែរ ក្នុងសំលៀកបំពាក់ប្រពៃណីខ្មែរ នៅដៃនាងមាន
កាន់ចានស្រាក់ដាក់ម្ហូបអាហារ ឯមីកឡោមីងឡេងកាន់ផ្កាទៀនធូប និងថាសដាក់
នំអន្សម ឯមីងសុតម្ដាយសារ៉ាន់ទូលថាសម្ហូបអាហាររួមដំណើរជាមួយ ។

សាវ៉ាន់ និងម៉េងចុះពីឡានទៅអញ្ជើញពូ និងមីងឡើងអង្គុយលើរថយន្តកៅអីខាងក្រោយ ពេលនោះម៉េង និងសាវ៉ាន់ស្រាប់តែភ្ញាក់ ព្រោះឃើញកូនម៉េងទាំងតូចទាំងធំ និងមិត្តភ័ក្តិវាស្រែកហោកញ្ជ្រៀវនៅពេញខាងក្រោយឡាន មិនដឹងពួកវាឡើងពួនជិះពីកាលណាមកទេ ។

ម៉េងពោលថា ៖

-សាវ៉ាន់ឯងឃើញទេពួកវាហ្នឹងមិនបានទេ !វាប៉ុនខាងលួចឆ្មក់ឡើងជិះណាស់ ការសម្ងាត់អីក៏លាក់ជាមួយពួកវាអត់ជិតដែរ ! ប៉ុន្តែកុំរវល់ពួកគេគិតរឿងសាវ៉ាន់ឯងទៅ !

ម៉េងក្រោយពីសំដែងការគួរសមតាមប្រពៃណីជាមួយចាស់ៗហើយ ក៏រៀបចំអោយពូនិងមីងអង្គុយស្រួលបួលឯខ្លួនគេ ក៏គេចទៅខាងមុខទុកអោយសាវ៉ាន់និងនាងសុណេតឈរមើលគ្នាខាងក្រោយឡាន ។នាងសុណេតខំសម្លឹងដៃសាវ៉ាន់ហើយសួរថា






_បងវ៉ាន់ដៃរបួសបាត់ឈឺហើយឬ ?

សាវ៉ាន់ភ្ញាក់ដាច់ការភ័នភាំង ហើយពោលតបស្រស់ស្រីវិញថា ៖

_អូ ! បាទ! នៅឈឺតិចៗដែរតែមិនអីទេបាទ !

នាងសុណេតញញឹមដាក់អ្នកកម្លោះបន្តិចហើយបំរុងឡើងជិះជាមួយពូមីងខាងក្រោយតែត្រូវសាវ៉ាន់ឃាត់ថា ៖

_ណេត ! កុំអី !ទៅជិតខាងមុខវិញ ! ពេលនោះមីងទៀងពោលទៅកាន់នាងណេតថា ៖

_បើសាវ៉ាន់គេហៅទៅជិះខាងមុខហើយទៅជិះទៅកូន !

សាវ៉ាន់ត្រេកអរណាស់ ស្ទុះទៅបើកទ្វារឡានខាងមុខអោយនាងសុណេតឡើង ។ ឯខ្លួនឯងក៏ឡើងទៅអង្គុយបៀតរូបនាង ។ នេះជាលើកដំបូងហើយដែលអ្នកកម្លោះបានអង្គុយក្បែរនារីជាទីគាប់ចិត្ត ដែលអ្នកធ្លាប់គិតឃើញតែក្នុងក្តីស្រម៉ៃថាបាននៅក្បែរបុប្ផស្រស់ប្រិមប្រិយ៍នេះឥឡូវក្តីស្រម៉ៃក្លាយជាការពិតហើយ ។ ប៉ុន្តែនៅជិតស្ងើយពេកដូច្នេះ អ្នកមិនដឹងត្រូវធ្វើអាកប្បកិរិយាយ៉ាងណាអោយសមទេ ។ តើភ្នែកដៃជើងអ្នកត្រូវធ្វើអីពេលនេះ ? មាត់ត្រូវនិយាយពាក្យអ្វី ?គិតចុះគិតឡើងសាវ៉ាន់នត្រឹមលួចមើលដៃនារីដែលដាក់សម្រឹមលើសំពត់ហូលដ៏រលើបរលោងរបស់នាង...ម្រាមដៃតូចៗដូចបន្លាម្រាមជើងធីតាដូចកែវចរណៃ ចុះទ្រូងនាងនិងកនាង ?ចុះវង់ភក្ត្រនាង ?។សាវ៉ាន់ងើយបន្តិចម្តងៗមើលរហូតដល់វង់ភក្ត្រនាងកញ្ញាក៏ប្រទះកែវភ្នែកដ៏ងតូរបស់ធិតាសម្លឹងចំមុខអ្នក......អ្នកកម្លោះបើកមាត់ពោលតិចៗថា ៖ ពុទ្ធោ !ណេត ! អូនល្អអ្វីម្ល៉េះ !

ធីតាសុណេតញញឹមអៀនប្រៀនហើយអោនមុខចុះម៉េងស៊ីហ្វេឡានទីនៀព្រោះដល់ផ្លូវបត់ចូលវត្តហើយ......សាវ៉ាន់នឹកស្តាយខ្លាំងណាស់ មិនគួរការធ្វើដំណើរនេះ

ខ្ញីពេកសោះចិត្តចង់អោយម៉េងបរឡានទៅមុខទៀត ។ម៉េងបរឡានទៅឈប់ក្នុងទីវត្ត ទាំងអស់គ្នាចុះចាករថយន្តដើរឆ្ពោះទៅសាលាបុណ្យ ។

ក្រោយពីរាប់បាត្រ និងប្រគេនចង្ហាន់ចំពោះព្រះសង្ឃរួចហើយ ក៏មានកម្លោះក្រមុំក្នុងភូមិមួយក្រុមដើរមកនិយាយរាក់ទាក់ជាមួយនាងសុវណ្ណេត ។ ពួកកម្លោះចោមរោមនិយាយកំប្លែងលេងសើចជាមួយនាង របៀបជាអ្នកស្គាល់គ្នាក្នុងភូមិ ហើយក៏មានកម្លោះខ្លះនិយាយផ្តែផ្តាំបែបស្និទ្ធស្នាលបណ្តាលអោយមានសំណើចគិលៗឡើង ។

ទាំងចាស់ទាំងក្មេងនៅក្នុងភូមិ អ្នកណាក៏គេស្រឡាញ់រាប់អាននាងសុវណ្ណេតដែរ ។ នាងជានារីប្រកបដោយចរិយាល្អប្រពៃណាស់ មិនចេះវាយឫកឆ្មើងឆ្មៃដាក់ញាតិមិត្តណាម្នាក់ឡើយ ។ ដូច្នេះហើយបានជាមិត្តសម្លាញ់ប្រុសស្រីមកចោមរោមនិយាយជាមួយនាង ធ្វើអោយនាងស្ថិតនៅកណ្តាលហ្វូងមិត្តភក្តិឃ្លាតឆ្ងាយពីសាវ៉ាន់។ ប្រការនេះ ធ្វើអោយសាវ៉ាន់កើតការស្រងូតស្រងាត់ក្នុងចិត្ត ឈរសម្លឹងពីចម្ងាយកើតក្តីច្រណែន ព្រោះខ្លួនពុំបានទៅនិយាយលេងជិតស្និទ្ធជាមួយនាង ដូចក្រុមមិត្តភក្តិនាង ។អ្នកកម្លោះឈរផ្អែកនិងសសរសាលា ភ្នែកសំឡឹងមើលទៅព្រះពុទ្ធរូបដែលមានព្រះភក្ត្រញញឹមសម្លឹងមករកអ្នក ។ ព្រះពុទ្ធអង្គទ្រង់ញញឹមស្រស់ ក៏ព្រោះព្រះអង្គទ្រង់ចូលបរិនិព្វានទៅហើយ ព្រះអង្គគ្មានបញ្ហាកំពុងចោទដូចរូបអ្នកទេ ។

នាងសុវណ្ណេតនិយាយសើចសប្បាយជាមួយមិត្តភក្តិប្រុសស្រី ហាក់ដូចជាភ្លេចថាមានយុវបុរសម្នាក់ឈរយ៉ាងកំសត់ខ្លួនចាំមើលនាង....។

សម្លេងស្គរបន្លឺឡើងជាសញ្ញាព្រះសង្ឃនិមន្តឆាន់ហើយ.......ពុទ្ធបរិស័ទទាំងប្រុសស្រីចាស់ក្មេងនាំគ្នាថ្វាយបង្គំព្រះសង្ឃ ដែលនិមន្តមកគង់ជាជួរនៅពីមុខស្តុកដែលពោរពេញដោយម្ហូបអាហារសម្បូរហូរហៀ ។ អាចារ្យលើកចង្ហាន់វេប្រគេនព្រះសង្ឃព្រះសង្ឃគ្រប់ព្រះអង្គបន្ទាប់មកព្រះសង្ឃក៏សូត្រសត្តប្បករណាភិធម្ម និងតិរោកុឌ្ឌសូត្រ



នាយម៉េងប្រមូលកូនតូចៗទៅដាក់ម្តុំ អោយប្រពន្ធ និងម្តាយក្មេកជាអ្នកមើល ហើយនាយឈរអើតរកមើលសាវ៉ាន់មិនឃើញសោះ មិនដឹងបាត់ខ្លួនទៅណា ។នាយក៏



សសៀវទៅសួរយាយសុតជាម្ដាយសាវ៉ាន់ យាយក៏គាត់ថាអត់ដឹងសាវ៉ាន់វាទៅណាដែរ ។ អម្បាញ់មិញឃើញសាវ៉ាន់ដុតធូបអង្គុយសំពះព្រះពុទ្ធរូប ហើយដើបចេញចាត់ទៅមិនដឹងទៅណាទេ ។ នាយម៉េងក្រឡេកមើលទៅនាងស្រណោត ឃើញនាងអង្គុយក្បែរឪពុកម្ដាយនាងកំពុងស្ដាប់លោកសូត្រ អត់ឃើញសាវ៉ាន់នៅជិតនោះទេ ។រកចុះរកឡើង ម៉េងខ្លួនឯងក៏បាត់កូនរបស់ខ្លួនអាធំៗមិនដឹងទៅណាដែរ ។ នាយក៏ចុះពីលើសាលាឆាន់មកដី ក៏ឃើញកូនស្រីមុំរបស់គេឈរយំម្នាក់ឯង ម៉េងលើកកូនពរហើយសួរថា ៖

_អាមុំឆីបានយំ ?

_បងម៉ីបងម៉ុងអត់អោយខ្ញុំទៅជាមួយទេ !

_ពួកគេទៅណា ?

_ពួកបងម៉ុងបងម៉ីទៅជាមួយពូវ៉ាន់ទៅលេងផ្ទះគាត់ ។

ម៉េងក៏យកកូនឡើងទៅលើសាលាវិញហើយចេះតែនឹកឆ្ងល់ថា ចុះហេតុអ្វីបានជាសាវ៉ាន់មិននៅក្បែរនាងស្រណោតបែរជានាំក្មេងៗដើរទៅឯណាទៅវិញ ។

នៅចំការក្រោយផ្ទះមីងសុតឯណោះ សាវ៉ាន់អង្គុយម្នាក់ឯងក្រោមដើមល្មុតនាមាត់ទន្លេ កំពុងបណ្ដែតអារម្មណ៍ទៅជាមួយនិងទឹកកំពុងហូរ ។ អ្នកកម្លោះកំពុងគិតក្នុងចិត្តថាតើនាងស្រណោតមានមនោសញ្ចេតនាយ៉ាងណាចំពោះអ្នក ? ឬមួយនាងរាប់អានអ្នកដូចជាមិត្តភក្តិធម្មតា ? នឹកទៅចង់តែសួរនាងអោយបានច្បាស់ ប៉ុន្តែមិនដាច់ចិត្តហាសួរ ខ្លាចក្រែងនាងឆ្លើយបដិសេធសេចក្ដីស្នេហារបស់អ្នក ពេលនោះអ្នកនិងក្លាយទៅជាយ៉ាងណា ? ពិតជាពិបាកគិតម្ល៉េះទេរឿងនេះ ។

កំពុងគិតស្មុងគំនិតស្រាប់តែពួកអាម៉ុះអាម៉ុងនិងគ្នាកនវ៉ា ពីរបីនាក់ស្ពាយផ្លែជំពូនិងកន្ទុតមួយថ្លក់ម្នាក់រត់មកជិតសាវ៉ាន់ហើយប្រាប់ថា ៖



_ពូវ៉ាន់ មីងណោតដើររកពូឯង ! ឥឡូវគាត់ដើរមកកាន់ទីនេះហើយ ! ពូឯងរត់ពួនទៅ !

សាវ៉ាន់ក៏ងើបគេចទៅពួននៅគល់ស្វាយ ឯក្មេងៗឯទៀតរត់ទៅពួនក្បែរៗនោះអស់ដែរ ។ នាងស្រណោតដើរមកដល់ ឈរក្រោមដើមស្វាយកន្លែងដែលសាវ៉ាន់ពួននាងខំរកមើលសាវ៉ាន់តែមិនឃើញសោះឯក្មេងៗមិនដឹងទៅណាស្ងាត់ឈឹង ។ នាងក៏ស្រែកហៅថា ៖

_បងវ៉ាន់ ! អឺបងវ៉ាន់ !

សាវ៉ាន់ខំសំងំស្ងៀមមិនឆ្លើយតបនារីរាមយង់ឡើយ ។ នាងនឹកឆ្ងល់មិនដឹងសាវ៉ាន់ទៅណា ហៅពីរបីដងមិនលឺឆ្លើយក៏បំរុងដើរទៅក្នុងផ្ទះវិញ ។ស្រាប់តែសាវ៉ាន់ស្ទុះមកយកដៃបិតភ្នែកនាងពីក្រោយ ។ ស្រស់ស្រីភ្ញាក់ស្រែកថា ៖

_បងវ៉ាន់លេងអីអាក្រក់ម្ល៉េះ ! ខ្ញុំខំតែភ័យ !

ក្មេងៗចេញពីគល់ឈើក្បែរនោះ ស្រែកហៅក្រវ៉ាអាម៉ុកូនច្បងរបស់ម៉េងអាយុ ១៣ ឆ្នាំវាស្រែកឡើងថា ៖

_ពូវ៉ាន់ចាប់មីងណោតបានស្រេច !

នាងក្រមុំមុខក្រហមដោយអៀនខ្មាស់ ដេញវាយក្មេងៗរត់ប្រសាចពេញចំការហើយរត់ទៅបាត់អស់ទៅ ។

សាវ៉ាន់នឹកភ័យខ្លួនក្រោយខ្លាចណោតអន់ចិត្ត ព្រោះខ្លួនបានយកដៃបិតភ្នែកនាងលេងបែបស្និទ្ធស្នាលជ្រុលហួស ។ តែផ្ទុយទៅវិញធីតានាងមានខឹងឯណា នាងគ្រាន់តែសំឡក់សាវ៉ាន់បែបខ្មាញ់តែប៉ុណ្ណោះ នារីក៏ធ្វើជាសួរសាវ៉ាន់ថា ៖

_បងវ៉ាន់ម៉េចបានមកផ្ទះម្នាក់ឯងចោលខ្ញុំនៅឯវត្ត ?

_អូ ! សូមទោសណាំណោត ដោយសារខ្ញុំឃើញណោតជាប់រវល់ជជែកលេងជា

បួយមិត្តភក្តិ ខ្ញុំក៏គេចមកកុំអោយរំខានណេត !។

-បងវ៉ាន់មិនទេ. ពួកទាំងអស់គ្នានាំគ្នាសរសើរខ្ញុំថាខ្ញុំឥឡូវមានសំណាងណាស់មានអង្គរក្សក្លាហានតាមការពារផង ។ ប៉ុន្តែអម្បាញ់មិញនៅក្នុងវត្ត ពេលខ្ញុំងាកមករកមើលអ្នកការពារនោះ ស្រាប់តែបាត់មុខតែម្តង !តើបងវ៉ាន់ឈប់ការពារខ្ញុំហើយឬ?

-ទេ ! មិនដូច្នោះទេ !បងពេញចិត្តនិងការពារអូនណេតជានិច្ច ! អោយតែអូនចាត់ទុកបង ... ង្គរក្សអូនទោះនៅទីណា ហោះលើមេឃ ឬមុជក្រោមសមុទ្រប្រយុទ្ធជាមួយនាគក៏បងមិនខ្លាចដែរ បងស្បថសុខចិត្តយកជីវិតបង ធានាការពារតែអូនម្នាក់ (សាវ៉ាន់ពោលហើយលើកដៃជាសញ្ញា) នាងកញ្ញាញញឹមខំតាមមើលកាយវិការអ្នកកម្លោះហើយអស់សំណើចយ៉ាងស្រួយស្រេះ ។

-ឥឡូវបានហើយ ! ខ្ញុំជឿចិត្តអង្គរក្សហើយ ពេលនេះខ្ញុំសូមអញ្ជើញលោកអង្គរក្សទៅពិសារបាយ !

-ទេអូនណេត ! ឈប់សិន !...អោយបងសុំបន្តិច....កម្លោះទាញខ្លួនតូចឆៅមកផ្អែកៗថ្នមៗនិងគល់ស្វាយ ហើយអ្នកបំរុងនិងអោនថើបថ្ពាល់ដ៏រណោងរបស់នាង។ ស្រស់ស្រីធ្វើជារើបំរះតិចៗ ប៉ុន្តែច្រមុះមិនទាន់បានដល់ថ្ពាល់ផង ស្នូរបាក់មែកជំពូព្រាវក្បែរនោះគឺពួកក្មេងៗវាលបមើលពីដើមជំពូ ពេលឃើញសាវ៉ាន់បំរុងថើបនាងសូណេតវាក៏ងណ្តើមគ្នាអើតមើល ទាល់តែបាក់មែកជំពូធ្លាក់មកដី ។ តែមែកនោះនៅទាបមិនមានបញ្ហាចំពោះពួកក្មេងរពឹសទាំងនោះទេ ។ នាងណេតមុខឡើងក្រហមដោយអៀនខ្មាស់ នាងធ្វើជារកពាក្យម៉កនិយាយ ៖

-បងវ៉ាន់ ! ព្រឹកមិញនៅលើសាលាបុណ្យ ខ្ញុំលឺអ៊ំឈុំគាត់ជំរាបពុកនិងម៉ែខ្ញុំនៅចំពោះព្រះភ័ក្ត្រព្រះសង្ឃ និងលោកអាចារ្យវត្តផងថា ខែក្រោយនេះគាត់សុំថៅកែឈប់ធ្វើការនៅក្រុមហ៊ុនហើយ ព្រោះគាត់ចាស់ហើយ ឯភារៈមេការប្រចាំក្រុមហ៊ុន



និងប្រចាំឃ្លាំង ថៅកែគាត់ថា និងប្រគល់អោយបងវ៉ាន់ឯងកាន់កាប់ជំនួសអ៊ំឈុំតទៅ ។ហើយនៅមានរឿងពិសេសផ្សេងទៀត តែខ្ញុំមិនអាចជំរាបបងបានទេ ទាល់តែ



បងទៅសួរម្ដាយបងទៅដឹងហើយ......... ។

សារ៉ាន់នឹកក្នុងចិត្តថា តើនៅមានរឿងអ្វីទៀតដែលធីតាស្វណោតបង្គាប់អោយគេទៅសួរម្ដាយរបស់គេនោះ ? រឿងនេះគង់តែដឹងច្បាស់នៅពេលដែលគេជួបម្ដាយរបស់គេមិនខាន ។

អ្នកទាំងពីរបណ្ដើរគ្នាចេញពីក្នុងចំការ សំដៅផ្ទះនាងស្វណោត ។ ចាស់ៗដែលកំពុងហូបបាយជុំគ្នាភ្លែកបាញ់តំរង់មកហើយខ្សិបគ្នាថា "សមគ្នាណាស់តើ !"

នាយម៉េងដែលប្រមូលក្មួនចៅទាំងសម្បុកមកហូបបាយទំរាំតែបានជុំគ្នានោះត្រូវទៅសែងក្រែ អ្នកជិតខាងមួយពីរមកផ្គុំគ្នាក្រោមដើមស្វាយដើម្បីដាក់ក្មួនមួយក្រោលនេះ ។ម៉េងក្រឡេកឃើញសារ៉ាន់បណ្ដើរនាងស្វណោតមកដល់ក៏ឆ្លៀតដើរមកជិតហើយខ្សិបដាក់ដាក់សារ៉ាន់ថា ៖

_នែ ! ឯងជោគជ័យហើយឬ ? គ្នាជួយអរ ! ប៉ុន្តែអាណិតថ្ងៃមុខកុំផលិតកូនច្រើនដូចគ្នាណា ! (នាងស្វណោតស្ដាប់លឺម៉េងខ្សិបដាក់សារ៉ាន់ដូច្នោះនាងអៀនក៏ដើរគេចចូលក្នុងផ្ទះបាត់ទៅ )។

សារ៉ាន់តបទៅម៉េងវិញថា ៖

_បងម៉េងរឿងខ្ញុំមិនទាន់ដឹងយ៉ាងម៉េចផង ដឹងជាម៉ែឪគេព្រមអោយឬយ៉ាងណា ?

ម៉េងពោលបន្តទៅទៀត ៖

_នែ ! ឯងអីក៏ឆោតម្ល៉េះ ? មកដល់ម៉ោងនេះទៅហើយនៅញញើមញញុំដល់ណាទៀត ! អោយម្ដាយឯងចូលស្ដីតែម្ដងទៅ ! ម៉េចចាំទាល់តែគេលើកទូលថ្វាយលោកឯងឬ ?

ចាត់ទុកជាសំណាងរបស់សារ៉ាន់ទៅចុះ ថ្ងៃនេះជាថ្ងៃបុណ្យភ្ជុំបិណ្ឌហើយក៏



ជាថ្ងៃជួបជុំគ្នាដោយចៃដន្យរវាងក្រុមគ្រួសារចឹកឡោ និងមីងសុតព្រមទាំងញាតិមិត្តរបស់សារ៉ាន់ មានម៉េង តាជិម មីងសៅនាងម៉ាចជាដើម ឯពូឈុំចាស់ទុំជាងគេគាត់ក្លាយជាគណៈអធិបតីនៃពិធីជួបជុំគ្នានេះ ។ ហើយពូឈុំនេះសោតក៏ត្រូវជាបងបង្កើតរបស់មីងទៀងម្ដាយនាងស្វណោតផងដែរ ។ អ្នកទាំងអស់គ្នាតែងស្ដាប់យោបល់ពូឈុំណាស់ ។ក្រោយពេលបាយរួច ពូឈុំក៏ចាប់ប្រាថ្ញព្រាកពីនេះពីនោះសារ៉ាន់ខំរកមើលមិនឃើញម្ដាយខ្លួននៅក្នុងចំណោមចាស់ៗទាំងនោះ ក៏ដើរប្រញាប់ទៅរកម្ដាយឯផ្ទះ។ ហើយសួរទៅម្ដាយថា ៖

_ម៉ែ ! ថ្ងៃនេះជួបជុំគ្នាល្អណាស់ ម៉ែយករឿងខ្ញុំទៅស្ដីចឹកឡោមីងទៀងអោយហើយទៅម៉ែ !ទាន់ឱកាសល្អ !។

មីងទៀងមើលមុខកូនដោយក្ដីអាណិតអាសូរ មីងយល់ចិត្តកូនប្រុសណាស់ទៅហើយ តែមីងមានបញ្ហាខ្លះត្រូវពិភាក្សាជាមួយសារ៉ាន់សិន ។ មីងពោលតបកូនវិញថា ៖

_សារ៉ាន់រឿងនាងស្វណោតនេះតាមម៉ែយល់មានបញ្ហាពីរដែលម៉ែចង់សួរកូន : បញ្ហាទីមួយ : រឿងម៉ែឪគេមិនជាអ្វីទេ តែចំណុចពិសេសវានៅត្រង់រូបកូនឯងនិងអឹឈុំប្រធានរបស់ឯងនោះ តើការងាររបស់កូនឯង និងកិរិយាមារយាទរបស់កូននៅកន្លែងធ្វើការបានជាទីពេញចិត្តរបស់អឹឈុំដែរទេ ? ព្រោះគុណសម្បត្តិទាំងពីរនេះហើយដែលវាហុចលទ្ធផលអោយកូនក្នុងថ្ងៃនេះ ។ ហើយបញ្ហាទីពីរគឺរឿងកូននិងនាងស្វណោត តើកូនបានស្ទង់ចិត្តនាងថាមានចិត្តលើកូនដែរឬទេ ?

សារ៉ាន់លឺម្ដាយពោលដូច្នោះក៏តបម្ដាយវិញថា ៖

_ម៉ែអើយគ្រាន់តែរឿងប៉ុណ្ណឹងក៏ម៉ែគេចមិនជួបជុំជាមួយគេ មិនហ៊ានសួរនាំគេខ្ញុំជំរាបម៉ែត្រង់ទៅចុះ ខ្ញុំបានទាក់ទងជាមួយអាណោតរួចហើយ ! ទាំងអស់គ្នាគេ

នៅចាំតែម៉ែទេតើ ! ចំណែកមាឈុំម៉ែកុំបារម្ភពីធ្លាខ្ញុំស្មោះណាំម៉ែ ។

-អើ ! បើអីចឹងចាំម៉ែទៅនិយាយអោយ !

សាវ៉ាន់ត្រេកអរណាស់ ឃើញម្តាយយល់ព្រមតាមបំណងខ្លួន នាយដើរតាមក្រោយម្តាយទៅផ្ទះនាងស្វណេតវិញ ។

ពេលនោះធីតាស្វណេតឈរ នៅមាត់បង្អួចក្រោយផ្ទះបក់ដៃហៅសាវ៉ាន់អោយទៅជិតសួរខ្សិបៗថា ៖

-បងសាវ៉ាន់ម៉ែបងចូលនិយាយជាមួយពុកខ្ញុំហើយឬនៅ ?

សាវ៉ាន់ខ្សិបថា ៖

-នៅទេអូន ! បងទើបទៅហៅគាត់មកពីផ្ទះមិញហ្នឹង !

-ម៉េចយូរម្ល៉េះបង ? អោយគាត់ចូលស្ដីរម៉ែពុកខ្ញុំថ្ងៃហ្នឹងទៅ ! ម៉ែពុកខ្ញុំគាត់ចាំតែយល់ព្រមតើ !

-មែនហ្អែ ? អូយបងសប្បាយចិត្តណាស់ណេតអើយ ! យប់ហ្នឹងអូនលបចេញមកក្រៅផ្ទះជួបបងបានទេ ?

-អេ៎ ! អត់បានទេ ! ខ្ញុំអត់ហ៊ានទេ ! យប់ម៉ែអត់អោយខ្ញុំចេញទៅក្រៅទេ !

-ខ្លាចអី ! យើងគង់តែប្តីប្រពន្ធតើ !

-កុំអី !បងវ៉ាន់ខ្លាចអ្នកស្រុកគេថាអោយខ្ញុំណា៎ មិនទាន់រៀបការផងហ៊ានចេញជួបប្រុសឈ្មោលអីៗទាំងយប់ណា៎ !

-បងចង់ជួបអូន ព្រោះបងមានរបស់មួយចង់អោយអូន !

-របស់អ្វីទៅបង ?

-អាខ្វាន់ !អីអាខ្វាន់ !(សម្លេងនាយម៉េងស្រែកហៅធ្វើអោយការសន្ទនាររវាងគូសង្សារទាំងពីរដាច់សាច់រឿងត្រឹមនោះ)



_អូ !វ៉ានៅទីនោះទេតើ !(ម៉េងស្ទុះទៅរកសាវ៉ាន់ហើយទះស្មាសាវ៉ាន់១ដៃ)

_បានការហើយ ! បានការហើយ !សំរេចហើយ !ម៉េងទះដៃសើចស្ញេញស្ញាញ

វ៉ាន់ខំសួរបញ្ជាក់ម៉េងថា ៖

_បានការស្អី ? សំរេចអីបង ?

_ម៉ែឪគេព្រមលើកកូនអោយឯងហើយណា៎ !

សាវ៉ាន់លឺម៉េងពោលដូច្នោះរំភើបខ្លាំងពេក ក៏សម្លឹងទៅបង្អួចមើលសង្សារបពួននៅក្បែរនោះ ។ ឯម៉េងគិតតែរ៉ាយរ៉ាប់តទៅទៀតថា ៖

_សាវ៉ាន់ឯងដឹងទេ , គ្រាន់តែម្តាយឯងទៅស្ដីរឿងឯងដល់គ្រួសារគេភ្លាមមាគាត់ឯកភាពភ្លែត ! អញឯណេះជួយប្រូលើកថែមទៀត ឯពូជិមមីងសៅបងម៉ាចណោះចាំបន្ទរតាមក្រោយទៀត ហះហា៎ !រឿងអីមិនជោគជ័យ ?ឥឡូវចាស់ៗកំពុងសថ្ងៃខែភ្ជាប់ពាក្យ និងរៀបការឯងក្នុងពេលឆាប់ៗនេះហើយ !។អញមានរឿងប្រាប់ងតែប៉ុណ្ណឹងទេ ឯងរវល់អីក្បែរបង្អួចនេះរវល់តទៅទៀតចុះគ្នាទៅវិញហើយ ! ។

ពោលហើយម៉េងដើរធ្វើង៉ើយ ទៅវិញបាត់ទៅ ។ ឃើញឱកាសស្ងាត់វិញហើយនាងកញ្ញាស្វណេតអើតតាមបង្អួចលូកដៃមកក្តិចសាវ៉ាន់ ដែលឈរខាងក្រៅហើយសួរថា ៖

_បងវ៉ាន់ថាមានរបស់អីអោយខ្ញុំ ? អោយភ្លាមមក !

សាវ៉ាន់ចាប់ដៃនាងជាប់ ហើយទាញរាងកាយនាងមក....តែគួរអោយស្តាយណាស់អ្នកកម្លោះពុំអាចទាញខ្លួនអោមនារីចេញមកក្រៅបាន ព្រោះចម្រឹងបង្អួចមាំណាស់ ។

នាយលូកដៃយកចិញ្ចៀន១វង់ពីក្នុងហោប៉ៅមកបំពាក់នៅម្រាមដៃនាង ស្រស់

ស្រីរំភើបក្នុងចិត្តណាស់ក៏សួរសារ៉ាន់ថា ៖

-បងរ៉ាន់បានប្រាក់ពីណាច្រើនម្ល៉េះទិញចិញ្ចៀនអោយខ្ញុំ ?

-ប្រាក់ខែបងណាំអូន !

-បងយកលុយទិញចិញ្ចៀនអោយខ្ញុំអស់ តើបងបានប្រាក់ឯណាចាយ ?

-មិនអីទេអូនបងនៅសល់ខ្លះដែរ . ចិញ្ចៀនតូចនេះវាមិនជាមានតម្លៃប៉ុន្មានទេ តែវាបញ្ជាក់ពីទឹកចិត្តបងដែលស្រឡាញ់អូនលើសលប់ ជាងអ្វីៗទាំងអស់លើផែនដីនេះណាំអូន !





សារ៉ាន់ពោលហើយគិតតែពីថើបដៃនាង និងចាប់អោបនាងពីក្រៅចម្រឹងដែកបង្អួច.......។

ឱ !សេចក្តីស្នេហា !បើលោជាបានតោងកគូស្នេហាណាមួយហើយ កុំអញ្ជើញត្រូណាទៅស្ពោះទៅផ្តុំ ទៅទាញមិនងាយរបេះទេ ។ ស្នេហាផ្អែមល្ហែមណាស់ដូចទឹកឃ្មុំខែចែត្រ. លោកម្ចាស់នេះបើបានជាចូលក្នុងរាងកាយមនុស្សហើយ នៅមិនស្ងៀមទេដើររុករានពេញក្នុងបេះដូងផ្តើមប្រមាត់មនុស្ស វាយសំពងអារម្មណ៍មនុស្សអោយយំ អោយសើច អោយភ័យ អរ កើតទុក្ខឈឺចាប់ខ្លោចផ្សារ ។ សព្វថ្ងៃនេះអស់លោកអ្នកនិពន្ធ-កវី មួយផែនដីចង់អស់ក្បាលនិង សរសេររៀបរាប់ពីរឿងស្នេហារបស់មនុស្សលោកដែលវិវត្តមិនឈប់ឈរ និយាយមិនចេះចប់សោះនេះ ។

ប៉ុន្តែទោះបីស្នេហាក្នុងលោកវិវត្តទៅយ៉ាងណាក៏ដោយក៏ស្នេហារបស់សារ៉ាននិងនាងស្វណេត ចាត់ទុកជាស្នេហាមានភ័ព្វសំណាងដ៏វិសេសវិសាលដោយឡែកមួយព្រោះស្នេហារបស់កម្លោះក្រមុំទាំងពីរនេះត្រូវមាតាបិតា ញាតកាទាំងសងខាងទទួលស្គាល់ និងសុខចិត្តរៀបអាពាហ៍ពិពាហ៍អោយអ្នកទាំងពីរក្នុងពេលឆាប់ៗខាងមុខនេះ។




មិនឆ្ងាយប៉ុន្មានពីទីរួមខេត្តកំពង់ស្ពឺ មានផ្ទះក្បឿងមួយខ្នងសង់របៀបផ្ទះកសិករជនបទ ស្ថិតនៅប្របមាត់ស្ទឹងហ៊ុមព័ទ្ធទៅដោយដើមឈើតូចធំ ចោលម្លប់ត្រឈឹងត្រឈៃនិងវាលស្រែដ៏ខៀវស្រងាត់ ។

ពូក្លយជាម្ចាស់ផ្ទះនេះអាយុប្រហែល ៥៥ឆ្នាំមានរបរធ្វើស្រែនិងឡើងត្នោត ។ ព្រឹកនេះគាត់មិនបានទៅមើលទឹកស្រែទេ ព្រោះជាប់រវល់ទទួលភ្ញៀវមកពីភ្នំពេញ ។ ព្រះអាទិត្យបញ្ចេញរស្មីចែងចាំងលើផ្ទៃទឹកស្ទឹង ដែលកំពុងហូរតូចត្របាញ់ ។ នៅពាក់កណ្តាលវស្សានរដូវផ្លូវច្រេះទឹកស្ទឹងឡើងពេញប្រៀបលិចព្រៃដែលដុះអមសងខាងស្ទឹងបង្កើតបានជាជំរកដ៏ល្អសំរាប់មច្ឆាគ្រប់ប្រភេទ ។

នាយខ្មៅ និងនាយតឿកាន់ផងសន្ទូចមួយម្នាក់អង្គុយនៅមាត់ស្ទឹងស្ទូចត្រី បានត្រីក្រាញ់ និងត្រីភ្លក់ពីរបីម្នាក់ ពូក្លឹងអង្គុយក្នុងខ្ទមតូចមួយជិតនោះកំពុងអោនផ្លុំភ្លើងជើងក្រានអាំងត្រីភ្លក់ដែលនាយតឿ និងនាយខ្មៅស្ទូចបាន ។

បន្តិចមកពូក្លយកាន់ឆ្នាំងបាយ និងចានដើរមកហើយវាចាថា ៖



-មកក្មួយៗ ! ល្មមដល់ពេលហូបបាយហើយ ! ក្មេងៗមកពីភ្នំពេញចូលចិត្តស្ងោរត្រីណាស់ ត្រីនៅស្ទឹងនេះសម្បូរក្រៃលែង ត្រីអីក៏មានដែរ ។ គេថាស្រុកខ្មែរយើងតែមានទឹកមានត្រីហើយ !។

-ត្រូវហើយ ! ប៉ុន្តែវាទាល់តែយើងឧស្សាហ៍ដែរទើបមានត្រីហូប មិនដែលត្រីណាវារត់ចូលចានសម្លរយើងទេ(ពូក្លឹងឧទាន) ។

-ប៉ុន្តែពួកលោកបងមកលេងម្តង ចាំបាច់ឧស្សាហ៍ធ្វើអី ! ត្រីប្រស់ទុកក្នុងពាងតគោកចង់ហូបត្រីអីក៏មានដែរ ចង់ប្រហុកក៏មានចង់មាំ ចង់ផ្អកកំពឹសក៏មានមាន់អាំងមាន់ដុតក៏បាន , ត្រឹមតែហូបមួយផ្អែតអត់ចេះខ្វះទេ !

នាយតឿ និងនាយខ្មៅលាងដៃប្រញាប់ប្រញាល់ ចូលមកអង្គុយហូបបាយនៅមាត់ស្ទឹងដែលមានខ្យល់បក់ត្រសៀកៗ ប្រកបដោយទេសភាពស្រស់ត្រកាល ។ វាលស្រែ ព្រៃភ្នំលាតសន្ធឹងវែងអន្លាយ ។ សត្វចាបព្រាបលលកហើរក្រោមផ្ទៃមេឃទូទឹមមើលទៅគួរអោយរំភើបរីករាយ នាំអោយការហូបបាយធម្មតាសោះ ក្លាយទៅជាពិធីជប់លាងមួយវិសេសបំផុត ។

ពេលហូបបាយរួចហើយ ពូក្លយងើបឡើងចង្អុលទៅឯនាយត្រើយម្ខាងស្ទឹងហើយរៀបរាប់ថា ៖

-ភូមិដែលយើងមើលទៅឃើញនៅត្រើយម្ខាងនោះហើយ ដែលពួកយើងត្រូវទៅជីកកំណប់យប់នេះ ។ ខ្ញុំបានរៀបចំទូកមួយសំរាប់ឆ្លងទៅ ។ យើងត្រូវរងចាំយប់បន្តិចទើបចេញដំណើរ ។

-អន្ទិតក្លយឯង មានបានទៅពិនិត្យទីតាំងកំណប់នោះច្បាស់លាស់ជាមុនហើយឬនៅ ?ព្រោះជិត ២០ឆ្នាំហើយអញវង្វេងកន្លែងបាត់ទៅហើយ ។អញសង្ឃឹមលើឯងហើយរឿងនេះ(ពូក្លឹងសួរបញ្ជាក់ពូក្លយ)។

-ខ្ញុំបានទៅពិនិត្យកន្លែងកំណប់នោះជាច្រើនដងហើយ ពុំទាន់មានអ្វីប្រែប្រួលទេ ។ កន្លែងកប់នោះខ្ញុំចាំច្បាស់ណាស់ គឺនៅចន្លោះដើមត្នោតនិងដើមព្រីង ។ ប៉ុន្តែថានិងគ្មានបញ្ហាអីសោះនោះក៏មិនបានដែរ ព្រោះកន្លែងកប់នោះនៅជាប់ក្រោយផ្ទះតាញ៉ៅញ៉ ដែលមានកូនក្រមុំម្នាក់ឈ្មោះនាងញ៉ៅ ។ហើយតាញ៉ៅញ៉េនេះបានធ្វើទ្រុងជ្រូកក្រោមដើមព្រីងចំកន្លែងកប់កំណប់នោះតែម្តង ។ ម្យ៉ាងទៀតប៉ុន្មានថ្ងៃនេះលឺថាយប់មួយនោះមានអ្នកកម្លោះជើងខិលលាក់មុខម្នាក់ បានលបចូលទៅក្នុងផ្ទះតាញ៉ៅញ៉ពេលតាទៅបុណ្យគេអ្នកផ្ទះជិតនោះ ។អាជើងល្អនោះវាបំរុងចាប់រំលោភនាងញ៉ៅកូនក្រមុំតាញ៉ៅញ៉តែមិនបានសំរេចទេដោយមានគេដឹងទាន់ ។ តាញ៉ៅញ៉និងអ្នកស្រុកកំពង់តែតាមដានរកចាប់អ្នកកម្លោះអាចិកំបាំងនោះរាល់យប់ ប៉ុន្តែរឿងនេះវាអត់ទាក់ទងអីនិងរឿងយើងទេ លោកបងកុំបារម្ភអី ព្រោះកំណប់នោះនៅក្រៅផ្ទះតាញ៉ៅញ៉យើងមិនចូលទៅក្នុងផ្ទះគាត់ទេ ។

-ឯងនិយាយថាមិនអីទេ កុំបារម្ភអីនោះអញស្តាប់បានហើយតែសំខាន់បំផុតគឺយើងត្រូវធ្វើកិច្ចការនេះអោយស្ងាត់ កុំអោយអ្នកណាឃើញអោយសោះ ។ គិតគ្នារួចស្រេចហើយអ្នកទាំងបួនប្រាណក៏សំរាករងចាំពេលរាត្រីមកដល់ និងអាលឆ្លងទូកទៅភូមិឯត្រើយម្ខាង ។

ម៉ោង ៩យប់ . ធម្មជាតិទាំងឡាយនៅតាមដងស្ទឹង សំងំស្ងៀមស្ងាត់ក្នុងផ្ទៃអន្ធការ ។ សត្វមៀមនិងខ្លែងស្រាក់បញ្ចេញសម្លេងម្តងៗគួរព្រឺក្បាល ។

ពួកអ្នកជីកកំណប់ទាំងបួននាក់ឡើងទូកតូចមួយ ហើយនាំគ្នាអុំឆ្លងទៅត្រើយម្ខាង....។

គេយកទូកទៅលាក់នៅគុម្ពព្រែងស៊ុបទ្រុបមួយ ។ ពួក្លយដៃម្ខាងកាន់ពិលដៃម្ខាងកាន់ចបជីកដើរនាំមុខអ្នកទាំង៣។គ្រប់គ្នាសុទ្ធតែកាន់ចបជីកមួយម្នាក់លើកលែង



តែនាយខ្មៅកាន់កាំភ្លើងខ្លីលាក់ក្នុងអាវ ។

ពួកគេដើរតាមភ្លឺស្រែ ដែលរអិលប៊ិចប៊ិចបាច់មួយសន្ទុះធំក៏បានទៅដល់ក្បែរផ្ទះអ្នកភូមិ ។ សម្លេងឆ្កែព្រុះធ្វើអោយអ្នកទាំងបួននាក់កាន់តែប្រុងប្រយ័ត្នឡើង ។

ពួក្លយអោយសញ្ញាទៅគ្នីគ្នាគាត់ឈប់សិនរួចចង្អុលទៅផ្ទះស្លឹកមួយខ្នង ដំបូលប្រក់ស័ង្កសីជាផ្ទះទាមនៅផ្ទាល់ដី ។ មានពន្លឺភ្លើងចង្កៀងប្រេងកាតជះចេញតាមប្រហោងជញ្ជាំងនិងចំរៀកបង្អួចមកក្រៅបញ្ជាក់ថាម្ចាស់ផ្ទះមិនទាន់សំរាកនៅឡើយទេ

ពួក្លយនិយាយខ្សឹបៗថា ៖

-ផ្ទះហ្នឹងហើយជាផ្ទះតាញ៉ៅញ៉ !ហើយទ្រុងជ្រូកនៅក្រោយផ្ទះគាត់ឃើញទេ? ឥឡូវយើងនាំគ្នាទៅពិនិត្យទ្រុងជ្រូកសិន !

ទាំងអស់គ្នាក៏ដើរលបៗក្នុងទីងងឹតសំដៅទ្រុងជ្រូក ។ពួក្លយកេះប្រាប់អាត្បៀនិងក្លឹងអោយយកចបចូលក្នុងទ្រុងជ្រូកជាមួយគាត់ឯនាយខ្មៅត្រូវនៅចាំយាមត្រង់គល់ត្នោតកាន់កាំភ្លើងការពារ និងអោយដំណឹងក្រែងអ្នកណាមក ។

ពួក្លយបញ្ចាំងពិលមើលឃើញជ្រូកនៅក្នុងទ្រុងនោះមានចំនួនបីក្បាលមានតូចមានធំ ។ អាធំជាងគេឃើញមនុស្សចំលែកចូលក្នុងទ្រុងវាក៏ផ្អើលស្ទុះងើបរត់ទៅក្បែរហើយស្រែកអ៊ូកៗ កូនវាតូចៗពីរក៏រត់ទៅតាមមេវា ។នាយត្បៀភ្ញាក់និងជ្រូកស្រែកដួលរកតូចហើយប្រុងងើបរត់ចេញពីទ្រុងខ្លាចជ្រូកខាំ តែត្រូវពួក្លឹងចាប់ទាញអាវជាប់ហើយខ្សិបថា ៖

-នៅអោយស្ងៀមកុំផ្អើល ! កុំខ្លាច ! ជ្រូកវាមិនចេះខាំទេ !

ស្ថភាពការណ៍ស្ងាត់ជ្រងំល្អណាស់ ពួក្លយបញ្ចាំងពិលទាបៗផ្ទាល់ដីមួលពន្លឺអោយតូចពិនិត្យទីតាំងកំណប់ ។

-កន្លែងនេះហើយ ! នៅក្រោមដើមព្រីងនេះប្រាកដណាស់ខ្ញុំចាំច្បាស់ ។ យើង

នាំគ្នាជីកទៅ  ដីប្រាយល្អណាស់(ពួកយខ្សិបប្រាប់អ្នកទាំងពីរ)។

នាយតៀធ្វើមុខថ្ងូរព្រោះស្អុយអាចម៍ជ្រូកពេកស្ទើរទ្រាំមិនបាន  វាយកអាវបិតច្រមុះនិយាយខ្សឹបៗទៅកាន់ពួក្លឹងនិងពួក្លយថា ៖

-ពួឯងទាំងពីរនាក់ជីកទៅ ! ខ្ញុំទៅចាំយាមនៅគល់ត្នោតជាមួយអាខ្មៅ !

-វាអាម៉េចឯង ! ចង់គេចទៅណា ?ស្អុយអាចម៍ជ្រូកប៉ុណ្ណឹងទ្រាំមិនបានឬ ? ក្រែងឯងចង់បានកំណប់ហ្អែ ?  ជីកជីភ្លាមទៅកុំរញីរញ៉ៃ  គេមកទាន់ខានជីកឥឡូវហើយ !។



សំណាងល្អដោយដីត្រង់ទ្រុងជ្រូកនេះប្រាយមានលាយរបាយខ្សាច់ច្រើនការជីកមិនជាលំបាកណាស់ណាទេ ។

អ្នកទាំងបីជីកបានជំរៅជាងកន្លះម៉ែត្រក៏ប្រទះនិងកេះគ្រាប់មួយ ។គេក៏ប្រញាប់ទាញកេះនោះឡើងមក  ។ កេះនោះធ្ងន់ណាស់មនុស្សម្នាក់លើកសឹងមិនរួច ។ ម្នាក់ៗ



នឹកថាក្នុងកេះនេះប្រាកដជាដាក់គ្រឿងមាសពេជ្រពេញណែន   ហើយបានជាធ្ងន់បែបនេះ ។

គេញ័រដៃញ័រជើងដោយក្តីត្រេកអរ   ខំសម្លឹងមុខគ្នាក្នុងទីងងឹតឃើញតែគ្រាប់ភ្នែកសព្រាតៗ ។

នាយតៀអរខ្លាំងពេកប្រុងស្ទុះងើបទៅប្រាប់អាខ្មៅតែត្រូវតាក្លយចាប់ជាប់....

-ឃីវាអាម៉េចឯងទៀតហើយ  នៅអោយស្ងៀមសិន ! ឃើញអាខ្មៅវាគប់ដុំដីអោយសញ្ញាមកហើយទេ ! ប្រាកដជាមានមនុស្សមកទីនេះមិនខាន  នៅអោយស្ងៀម។នុះហ៎្មានគេដើរមកមែន !។

ពេលនោះនាយខ្មៅបានគប់ដុំដីអោយសញ្ញាជាលើកទីពីរអោយអ្នកទាំងបីដែលនៅក្នុងទ្រុងជ្រូកនៅអោយស្ងៀមមានគេដើរមកហើយ  ។  ទាំងបីនាក់សំងំក្រាបនៅក្បែនទ្រុង ។អ្នកស្រុកបីនាក់ដើរតាមផ្លូវតូចក្រោយភូមិ មកដល់ជិតទ្រុងជ្រូកដោយមានវាយទ្រុងដាក់កង្កែបនិងកាន់កាំបិទផ្គាក់ម្នាក់មួយព្រមទាំងពិលឆ្កុះកង្កែបផង។ពួកគេជែកគ្នារឿងសព្វៗពុំបានចាប់ភ្លឹកថាមានមនុស្សនៅក្នុងទ្រុងជ្រូកទេ ។

ចៃដន្យអីពេលអ្នកឆ្កុះកង្កែបទាំងបីរនាក់ដើរមកដល់ទន្ទឹមនិងទ្រុងជ្រូក.មេជ្រូកដើរមកនោមក្បែរអាតៀ  ។   ទឹកនោមជ្រូកភាយក្លិនឈ្ងួលច្រមុះអាតៀកំពុងក្រាបណ្តាលអោយវាកណ្តាសលឺផែតៗពីរបីដង ។អ្នកស្រុកបីនាក់ដែលដើរមិនទាន់ផុតទ្រុងជ្រូកផងក៏ភ្ញាក់ងាកមកមើលទ្រុងជ្រូកហើយចុចពិលបញ្ចាំងទៅក្នុងទ្រុងឃើញមនុស្សលែកបីនាក់ក៏ស្រែកសួរថា ៖

-អ្នកណាហ្នឹង ?

លឺសម្លេងស្រែកសួរដូច្នេះ  តាក្លយគ្មានឱកាសតបសំដីវិញទេ  ស្ទុះរឹងទាញកេះ

គ្រាប់អោបរត់ភឹងទម្លាយទ្រុងជ្រូកបាតជើងសព្រាត កាត់វាលស្រែសំដៅស្ទឹង ។ ឯតាក្លឹងរត់តាមក្រោយហត់តយ្ហ ។

ចំណែកអាតឿវារត់ចេញពីទ្រុង ស្ទន់ពេកបោលចូលទៅពួននៅគល់ចេកក្បែរនោះតែដើមចេកតូចៗពេក ពួនមិនបាត់ខ្លួនក៏រត់ចេញមកវិញ វាចំណាំភូមិសាស្ត្រមិនបានណាយប់ងងឹតផងមិនដឹងជាទៅផ្លូវណា សម្លឹងឃើញបន្ទប់ទឹកជាប់ក្រោយផ្ទះតាញ៉ាញ់ក៏ចូលជ្រកក្នុងនោះយករួចខ្លួនសិន ។

នាយតឿចូលទៅក្នុងបន្ទប់ទឹកក៏ជួបវ៉ាក់និងនាងញ៉ិកូនស្រីតាញ៉ាញ់កំពុងងូតទឹកចោមពង់ក្រមាខ្លីកំបុិតលេចឈើស្មើរក្រោម អង្គុយដុះក្អែលនៅក្បែរពាងទឹក ។ នាងញ៉ិភ្ញាក់ក្រញ៉ាងឃើញនាយតឿចូលមក ។ដោយក្រមានាងខ្លីពេកមិនដឹងថាត្រូវយកដៃខ្ទប់ត្រង់ណាចោលត្រង់ណា ក៏បើកភ្នែកធំៗ ខំសម្លឹងមើលអាតឿមាត់នាងបំរុងនិងហាស្រែក......តែនាយតឿស្ទុះទៅយកដៃខ្ទប់មាត់នាងជាប់កុំអោយស្រែក ហើយអោបនាងញ៉ិជាប់និងពាងទឹកកុំអោយរើ ។

នៅខាងក្រោយផ្ទះឯណោះ អ្នកស្រុកកំពង់ដេញតាមចាប់ពួក្លយ និងពូក្លឹងដោយច្រឡំស្មានថាចោរលួចជ្រូក ។ សម្លេង "ចោរ ! ៗ ចោរលួចជ្រូក" "ជួយចាប់ចោរផង !"លាន់លឺពេញភូមិ ។អ្នកភូមិផ្អើលមកខ្លះកាន់ដំបងខ្លះកាន់ផ្គាក់ដេញប្រផាប់ចាប់ប្រភឹង ។ ប៉ុន្តែដោយយប់ងងឹតពេក ក៏បានឱកាសអោយពូក្លយ និងពូក្លឹងដកឃ្លារត់ទៅដល់មាត់ស្ទឹង ។ ពូក្លយអោបកេះគ្រាប់ជាប់លើកដាក់លើទូកប្រញាប់ប្រញាល់ឯពូក្លឹងក៏ដោលទូកចេញពីច្រាំង ។ ចំណែកអាខ្មៅកាន់កាំភ្លើងរត់មកដល់មាត់ស្ទឹងឃើញទូកចេញផុតច្រាំងបន្តិចទៅហើយ ក៏សិកកាំភ្លើងនៅចង្កេះខោហក់ប្រូងចុះទឹកហែលសំដៅទៅចាប់គែមទូក តែដោយទឹកហូរខ្លាំង នាយស្រវាតោងឡើងដោយលំបាក ។ សម្លេងកាំភ្លើងរបស់ជីវពលភូមិ លាន់លឺផ្ទួងៗសំដៅមកមាត់ស្ទឹងលាយ





និងសំរែក "ឈប់សិនកុំរត់" ធ្វើអោយនាយខ្មៅភ័យកាន់តែខ្លាំង ។ ពូក្លឹងនិងពូក្លយប្រឹងទាញដៃនាយខ្មៅឡើងទូកទាំងស្ទន់ស្ទោខ្លាចគ្រាប់កាំភ្លើងបាញ់មកត្រូវ ។ទឹកហូរតួចទូកវិលវល់ត្រឡប់ត្រឡិន ។ នាយខ្មៅខំប្រតោងឡើងលើទូក ឯកាំភ្លើងស៊ៀតនៅចង្កេះខោនោះក៏ទាក់និងគែមទូក របូតធ្លាក់ទៅក្នុងទឹកស្ទឹងបាត់ទៅ ។

ទូកអ្នកស្រុកនិងសេនាជនដេញតាមប្រកិតទូកអ្នកទាំងបី ។ អ្នកខ្លះរត់តាមមាត់ច្រាំងបញ្ជាំងពិលមកព្រោងព្រាត ។ដោយស្ទឹងមានទំហំតូចទីបំផុតអ្នកទាំងបីក៏ត្រូវគេចាប់ខ្លួនបាន ។

នៅឯបន្ទប់ទឹកផ្ទះតាញ៉ាញ់ឯណោះ តាញ៉ាញ់និងប្រធានភូមិកាន់ត្បោងមួយម្នាក់ចង្កុលមុខនាយតឿ ដែលឈរធ្វើភ្នែកភ្លឺសៗប្រឹងយកដៃខ្ទប់មាត់នាងញ៉ិតែនាងញ៉ិឃើញឪពុកនិងប្រធានភូមិមកដល់ក៏របើពីនាយតឿរត់ទៅក្នុងផ្ទះបាត់ទាំងក្រមាខ្លី ។

តាញ៉ាញ់យាឡោងកំញើញនាយគឿ ៖

-យើ ! អាក្បាលខូច ! អញរកតែមុខទេតើ ! ហ៊ានចូលផ្ទះអញលបចាប់កូនអញផងឬ ? មុខមើលតែឆ្មារអោងអីក៏ថ្លើមធំម្ល៉េះ ? អញសំពងក្បាលឯងបែកជាប្រាំពីរភាគឥឡូវហ៊ី !...(តាញ៉ាញ់ធ្វើជាយាឡោងយ៉ាងខ្លាំងសំដៅនាយគឿ តែគាត់ពុំបានវាយចំទេគ្រាន់តែជន្ល ហើយវាយទៅលើជញ្ជាំងក្បែរនាយគឿប្រាវៗ )។

នាយគឿមុខប្រលាក់ភក់អាចម៍ជ្រូកស្រមាំម សល់តែប្រឡេះភ្នែកប្រឹងគេចពីឡោងតាញ៉ាញ់ ។ ប្រធានភូមិរារាំងឃាត់តាញ៉ាញ់ ៖

-លោកបង ! ឈប់សិន ! កុំអាលច្រឡោតនិយាយរកខុសត្រូវសិន !

-កុំឃាត់លោកប្អូន ! ទុកអោយខ្ញុំដាក់អាហ្នឹងអោយស្គាល់ឡោងខ្ញុំម្តង !ហ៊ី... អាហ្នឹងហើយមកលបកូនអញថ្ងៃមុន !។

តាញ៉ាញ់ដេញតាមនាយគឿ នាយគឿរត់គេចជុំវិញប្រធានភូមិ ហើយរត់តំរង់រាំងនាងញ៉ីទាំងមុខស្រមាំមដូចក្តាមប្រែ ។

ប្រធានភូមិទាញតាញ៉ាញ់ចង់របូតខោខ្លួនឯង , ឯតាញ៉ាញ់ទាញរាំងននបើករកមើលនាយគឿហើយយាដំបងវាយនាយគឿត្រូវរាំងននដាច់ធ្លាក់មកដីខ្ទុក ។នាយគឿភ័យកាន់តែខ្លាំង រត់ឡើងលើគ្រែនាងញ៉ីជាន់នាងញ៉ីដែលកំពង់ផ្លាស់សំពត់ ។នាងញ៉ីស្រែកយ៉ៃ ! ។ នាយគឿទាល់ច្រកហក់ប្រតោងឡើងលើធ្នឹមផ្ទះ ហើយអង្គុយនៅលើធ្នឹមនោះទៅព្រោះគ្មានផ្លូវរត់ទៀតទេ ។

ប្រធានភូមិឃាត់តាញ៉ាញ់បានហើយ ស្រែកហៅនាយគឿអោយចុះពីលើធ្នឹមផ្ទះមក ។នាយគឿគ្រវីដៃគ្រវីក្បាលប្រកែក ព្រោះឃើញតាញ៉ាញ់បើកភ្នែកទឹទុយមើលមក ។



ប្រធានភូមិសួរនាយតឿថា ៖

-ក្មួយឯងឈ្មោះអី ? នៅភូមិណា ?

-ខ្ញុំឈ្មោះតឿ ?ទីលំនៅ . នៅភ្នំពេញ !

-ហេតុអីបានជាឯងមកចូលក្នុងផ្ទះនេះ ? ឯងប្រុងលួចស៊ីគេ ?ឬបំរុងចាប់កូនក្រមុំគេ ឆ្លើយអោយត្រង់មក ! (ប្រធានភូមិសួរបញ្ជាក់នាយតឿ)។

-អត់ទេលោកមា ! ( នាយតឿវាដៃប្រកែកទាំងគ្រវីក្បាលផង ) ខ្ញុំអត់មានបំណងបួច្ចេះទេរឿងនេះដែនទ្យទេ ! សូមកុំចោទខ្ញុំបួច្ចេះ ខ្ញុំជាមនុស្សល្អទេ !

ការសួរចម្លើយក៏ត្រូវបង្អាក់ ដោយមានអ្នកភូមិនិងជីវពលមួយក្រុមមកដល់មុខផ្ទះតាញ៉ៅញ់ . ប្រធានភូមិសួរទៅអ្នកភូមិថា ៖

-ម៉េចទៅចាប់ចោរលួចជ្រូកបានហើយឬនៅ ?

-ចាប់បានហើយតែមិនមែនចោរលួចជ្រូកទេលោកបងអើយ !( អ្នកភូមិម្នាក់ឆ្លើយ)

-អើបើមិនមែនចោរលួចជ្រូកជាអ្នកណាទៅវិញទៅ ? ប្រធានភូមិសួដោយឆ្ងល់ . អ្នកភូមិក៏ឆ្លើយថា ៖

-យើងចាប់ច្រឡំទេ ! តាមពិតគឺលោកបងក្លយនៅខាងកើតស្ទឹងគាត់នាំគ្នីគ្នាមកជីកកំណប់នៅក្រោយផ្ទះអ៊ុញ៉ៅញ់ហ្នឹងណាំ !

-ចុះបើជីកកំណប់ ម៉េចចាំបាច់រត់ធ្វើអី ?

-គាត់ជីកកំណប់ស្ងាត់ៗមិនចង់អោយគេឃើញដល់គេមកឃើញគាត់រត់តែម្តងទៅ !(ជីវពលម្នាក់តប)

ប្រធានភូមិរអ៊ូតិចៗថា ៖



ចំតែម្តងលោកបងក្លយ ធ្វើអោយផ្អើលអស់មួយភូមិមកជីកកំណប់មិនប្រាប់គេឯងអោយដឹងផង ! សំណាងល្អហើយ ដែលជីវពលបាញ់មិនត្រូវកុំអីវីវរតែម្តងហើយនេះ។(គាត់រអ៊ូហើយបែទៅសួរជីវពលនិងអ្នកភូមិថា) ៖

-ឥឡូវក្រុមគាត់នៅឯណា ?

-បាទនៅមាត់ស្ទឹងឯណោះ គាត់ថាគ្នាគាត់ទាំងអស់មានបួននាក់ឥឡូវបាត់ម្នាក់មិនដឹងរត់ទៅពួនឯណា កំពុងចាត់គ្នាតាមរក !

ប្រធានភូមិអស់សំណើចចង្អុលទៅនាយតឿដែលអង្គុយនៅលើថ្នឹមផ្ទះតាញ៉ៅញ់ហើយពោលថា ៖

-គ្នាគាត់បាត់ម្នាក់ហ្នុង គឺអន្ទិតហ្នឹងហើយមែនទេ ? អញ្ជើញចុះមកលោកធំកុំនៅខ្ពស់ពេក ! ផុតទុក្ខផុតភ័យហើយ ! ចុះមក(ប្រធានភូមិបក់ដៃហៅនាយតឿ)

អ្នកភូមិនិងជីវពលនាំគ្នាសើចគិល ឃើញនាយតឿនៅលើថ្នឹមផ្ទះមុខស្រមាំមរួចត្លុកល្ងោន ។

នាយតឿសំរូតចុះមកដីសើចស្ងេញស្ងាញក្នុងចិត្តត្រេកអរក្រៃលែង ប៉ុន្តែមកនឹកឮញៀតនិងតាញ៉ៅញ់ចេះតែលួចចោលកន្ទុយភ្នែកមើលទៅតា ឃើញគាត់កាន់ត្នោងគោះនៅបាតដៃប៉ូកៗ ធ្វើមុខមាំសម្លឹងមក ។ ប្រធានភូមិសួរបញ្ជាក់នាយតឿថា ៖

-ក្មួយឯងមកជីកកំណប់ជាមួយលោកបងក្លយដែរមែនទេ ?

-បាទ !

-តើកំណប់នោះជីកបានហើយឬនៅ ?

-បាទជីកបានកេះគ្រាប់មួយមិនទាន់បានបើកមើលផងក៏ផ្អើលរត់ទៅពូក្លយគាត់អោបកេះគ្រាប់នោះរត់ចោលខ្ញុំទៅបាត់ខ្ញុំអត់ស្គាល់ផ្លូវរត់ព្រោះយប់ងងឹតពេកក៏រត់ចូល

ផ្ទះនេះតែម្តងទៅ

ប្រធានភូមិងាកទៅតាញ៉ាញ់ហើយពោលថា ៖

-លោកបង ! តាមចម្លើយក្លួយនេះ គេមិនមានបំណងចូលក្នុងផ្ទះលោកបងទេ គេមកតាមលោកបងក្លួយដើម្បីជីកកំណាប់តែប៉ុណ្ណោះ ។ប៉ុន្តែក្លួយឡើនេះក៏មានកំហុសតាមផ្លូវច្បាប់ដែរ ព្រោះមកជីកកំណាប់នៅក្នុងភូមិគេមិនប្រាប់ម្ចាស់គេអោយដឹងមុន ! ដូច្នេះត្រូវទៅដោះស្រាយគ្នានៅឯទីស្នាក់ការភូមិឥឡូវនេះ ។

តាញ៉ាញ់បន្ថែមសំដីថា ៖

-លោកប្អូនប្រធានភូមិ អាល្អិតនេះមានកំហុសដល់ទៅពីររឿងឯណោះ មិនមែនមួយរឿងទេ !រឿងជីកកំណាប់ផង ហើយរឿងមួយទៀតគឺរឿងវាចាប់មីនាងកូនខ្ញុំនៅក្បែរពាងទឹក !

-មិនអីទេ ! លោកបងកុំព្រួយ ! ចាំខ្ញុំនាំអន្ទិតឡើនេះទៅដោះស្រាយគ្នានៅឯទីស្នាក់ការភូមិអោយបានរួចរាល់យប់នេះតែម្តង ។

អ្នកស្រុកទាំងក្មេងទាំងចាស់ទាំងប្រុសទាំងស្រីលឺថាគេជីកកំណាប់បានក៏ផ្អើលឈូឆរដើរត្រសងទៅកាន់ផ្ទះប្រធានភូមិ នាំអោយឆ្កែភ្ញាក់ព្រួសពេញភូមិ ។

នៅទីស្នាក់ការដែលតាំងនៅក្រោមផ្ទះប្រធានភូមិតែម្តងនោះ គេបាននាំពួក្លយពួក្លឹងនឹងនាយខ្មៅទៅទីនោះដែរ ។

ពួក្លយលីកេះគ្រាប់ទៅដាក់លើកន្ទេលស្លឹកត្នោតមួយដែលក្រាលកណ្តាលទីស្នាក់ការ ។

អ្នកភូមិប្រជ្រៀតគ្នាខ្លាំងណាស់ ព្រោះចង់មើលកំណាប់សឹងធ្លាយជញ្ជាំងធ្លាយទ្វារទីស្នាក់ការ ។ក្មេងៗរោមជុំវិញអ្នកជីកកំណាប់ឡើងខ្មៅងងឹត ។ទ្រាំមិនបានប្រធាន



ភូមិក៏បង្គាប់អោយជីវពលដេញអ្នកមើលទាំងក្មេង ទាំងចាស់ ចេញក្រៅទីស្នាក់ការហើយបិតទ្វារដាក់គន្លឹសពីក្នុងជាប់ ។

ម៉ាស៊ីនភ្លើងមួយគ្រឿងត្រូវបានគេខ្ចីយកពីវត្តមកបញ្ឆេះដាក់អំពូលម៉ែត្រ ពីរបីអោយភ្លឺថែសម្ងួចពន្លឺថ្ងៃស្រួលមើលកំណាប់នៅក្នុងកេះ ហើយត្រូវបើកមើលឥឡូវនេះ។

ប្រុងប្រៀបរួចហើយប្រធានភូមិ និយាយទៅកាន់អ្នកជីកកំណាប់ទាំងបួននាក់ថា ៖

-លោកបងក្លួយ !ដើម្បីបញ្ជាក់អោយអ្នកភូមិគេជឿជាក់ថាលោកបងមិនមែនជាចោរលួចជ្រូកទេ គឺជាអ្នកជីកកំណាប់វិញនោះ សូមលោកបងបើកកេះគ្រាប់នេះមើលតើមានវត្ថុអ្វីខ្លះនៅក្នុងនោះ ! សូមអញ្ជើញលោកបង !។

ពួក្លយលឺប្រធានភូមិបញ្ជាដូច្នោះក៏ងាកមើលមុខពួក្លឹងនិងសហការីគាត់ទាំងពីរដើម្បីអោយជួយបញ្ចេញយោបល់ជំទាស់ឡើង ។ ពួក្លឹងក៏បញ្ចេញទស្សនៈរបស់គាត់ថា ៖

-ពួកយើងពុំអាចធ្វើតាមសំណូមពររបស់ប្អូនប្រធានភូមិបានទេ ព្រោះដូចយើងបានជំរាបបងប្អូនទាំងអស់គ្នាហើយថាពួកយើងមកយកតែរបស់របរដែលយើងកប់ទុកពីសម័យមុនតែប៉ុណ្ណោះ ក្រៅពីនេះយើងគ្មានទាក់ទាមចង់បានស្អីនៅទីនេះទៀតទេ !។

ទាំងប្រធានភូមិទាំងជីវពលនៅតែទទូចអោយពួក្លយពួក្លឹងគាស់កេះមើលទោះបីអ្នកទាំងបួនប្រកែកជំទាស់យ៉ាងណាក៏ដោយ ។

មើលទៅពុំអាចរារាំងបំណងរបស់ប្រធានភូមិ និងជីវពលបាន ពួក្លយក៏ចាប់ផ្តើមយកមុខពូថៅទៅគាស់កេះគ្រាប់នោះ......

កេះគ្រាប់ដែលកប់ក្នុងដីយូរឆ្នាំ មានសភាពច្រេះស៊ីជាប់រង្វង់មាត់កេះ គាស់

សឹងមិនរបើក ។ នៅពេលដែលគម្របកេះរបើកឡើងម្នាក់ៗដែលស្រមៃឃើញថាមាសនៅពេញកេះនោះ  បែរជាខកបំណងរៀងៗខ្លួន ព្រោះនៅក្នុងកេះនេះមានសុទ្ធតែដែកគោលច្រេះនិងក្បាលខ្សោស៊ីចាស់ៗពេញណែនហើយគ្មានមាសប្រាក់បន្តិចណាឡើយ។

ពូគ្រឹង ពូគួយ នាយតឿ នាយខ្មៅខកចិត្តយ៉ាងខ្លាំងនាំគ្នាដើរចេញទៅអង្គុយនៅក្បែរជញ្ជាំង  អស់សង្ឃឹមចង់ខ្យល់ចាប់បន្តិចចង់យំបន្តិច  ស្តាយកំលាំង ស្តាយគំនិតដែលគិតពីនាយផ្លាក់អាយ  មកលំបាកលំបិនអត់បានការអីសោះ ។

អ្នកស្រុកហួសចិត្តគ្រប់គ្នា   បបួលកូនជញ្ជូនចៅត្រឡប់ទៅផ្ទះវិញអស់ស្វាត់ទីស្នាក់ការនៅសល់តែប្រធានភូមិ និងកងជីវពលប៉ុន្មាននាក់  ជាមួយនិងអ្នកជីកកំណាប់ខកចិត្តទាំងបួនប្រាណ ។

ប្រធានភូមិនិងសហការីរបស់គាត់ដែលម្នាក់ៗសង្ឃឹមញញឹមទុកថា យ៉ាងណាក៏បានភាគផលខ្លះៗពីកំណាប់មួយកេះនេះគ្រាន់សើមមាត់ដែរ    ឥឡូវបែរទៅជាអត់នោះមិនអស់ចិត្តក៏សួរបញ្ជាក់ពូគួយនិងពូគ្រឹងថា ៖

-មើល៍លោកបង !រឿងកំណាប់ហ្នឹងវាយ៉ាងម៉េចបានជាវាក្លាយជាដែកគោលអីចឹង ?ឬមួយលោកបងទាំងពីរច្រឡំកន្លែង ?សូមមេត្តារៀបរាប់ប្រភពដើមនៃកំណាប់នេះផងមើល៍ !។

ពូគ្រឹងចាប់រៀបរាប់រឿងកំណាប់នេះដូចតទៅ ៖

ក្នុងខែមេសាឆ្នាំ ១៩៧៥ ពេលខ្មែរក្រហមមានជ័យជំនះលើរបបលោកលន់ណុលហើយចូលកាន់កាប់ប្រទេសកម្ពុជាទាំងមូលនោះ . ខ្ញុំនិងអន្ទិតគួយបានភៀសខ្លួនចេញពីក្រុងកំពង់ស្ពឺជាមួយអ្នកមានម្នាក់  ដែលមានមុខរបរជាថៅកែរោងអារឈើក្នុងខេត្តកំពង់ស្ពឺនេះ ។



ដោយខ្ញុំពីរនាក់អន្ទិតគួយជាកម្មកររបស់គាត់ពេលគាត់ទៅណាយើងតែងតាមការពារគាត់ជានិច្ច ។

យប់មួយនោះយើងបានសំរាកនៅភូមិនេះ ។ពេលពាក់កណ្តាលអាធ្រាត្រលោកថៅកែបានពឹងខ្ញុំពីរនាក់អន្ទិតគួយ  អោយជីកដីក្រោមដើមព្រីង  ដែលយើងបានគាស់កំណាប់អម្បាញ់មិញ  ពួកយើងបានធ្វើតាមបញ្ជាគាត់  ជីកដីរួចហើយគាត់បានអោយយើងចេញមកឈរយាមនៅឆ្ងាយពីកន្លែងកប់នោះ។ចំណែកគាត់និងប្រពន្ធកូនគាត់បានយកមាសប្រាក់របស់របរមួយហិបធំមិនដឹងថាមានប៉ុន្មានទេយកទៅកប់លាក់ទីនោះ ។

ស្អែកឡើងពួកយើងក៏បែកពីគាត់និងក្រុមគ្រួសារគាត់ទៅនៅសហករណ៍ផ្សេងៗពីគ្នា ។ ក្រោយមកលឺថាគាត់និងក្រុមគ្រួសារបានត្រូវគេសម្លាប់អស់ហើយ ។

ក្រោយថ្ងៃ ៧មករា ១៩៧៩  ខ្ញុំបានចូលមករស់នៅក្រុងភ្នំពេញរហូតមកពុំបាននឹកនាដល់កំណាប់នេះទេ  ។ ទើបតែប៉ុន្មានខែនេះ  អន្ទិតគួយបានមកបបួលខ្ញុំអោយមកជីកយកកំណាប់នេះ ។ មិននឹកស្មានសោះ  ថាកំណាប់មាសវាប់តឹឡូវក្លាយជាដែកគោលដូច្នេះ ។នេះហើយដែលគេហៅថា មនុស្សអត់សំណាងគ្មានលេខត្រូវបានស៊ីរបស់ទ្រព្យគេទេ ។

ពេលនោះតាញ៉ាញ់និងកូនគាត់នាងញីដែលនៅសំកុកចាំស្តាប់ខាងក្រៅទីស្នាក់ការក៏ដើរចូលមកហើយពោលថា ៖

_អាហ្នឹងហើយជីកកំណាប់ក្នុងដីភូមិគេ  មិនប្រាប់ម្ចាស់គេមាសវាក្លាយជាដែកគោលអីចឹងបានសមមុខ !

តាញ៉ាញ់ពោលបានពីរបីម៉ាត់  ក៏ស្រាប់តែលេចមុខតាអាចារ្យវត្តដើរកាន់ឈើច្រត់និងពិលចូលមកក្រោយគេ   ព្រោះលឺថាគេជីកបានកំណាប់  តែកំណាប់នោះក្លាយ

ជាដែកគោល គាត់មានការងឿងឆ្ងល់ក៏មកសួរនាំរឿងនេះ ។ ប្រធានភូមិជំរាបតាអាចារ្យតាមដំណើររឿង តាអាចារ្យស្តាប់ការរៀបរាប់របស់ប្រធានភូមិសព្វគ្រប់ហើយ ក៏អស់សំណើចយ៉ាងខ្លាំង ហើយគាត់រើសដែកគោលធំៗ ដែលទើបចាក់ចេញពីគេះគ្រាប់នោះបានមួយក្តាប់ដៃយ៉ាងណែន ដាក់ទុកមួយកន្លែងធ្វើព្រងើយហើយពោលឡើងថា ៖

_ដែកគោលនេះធំល្អណាស់ សុទ្ធតែជារបស់ពីសង្គមទោះបីច្រេះស៊ីបន្តិចបន្តួចតែនៅមាំអាចប្រើការបាន ខ្ញុំកំពុងរកដែកគោល ១គីឡូទៅជួសជុលគ្រែនៅសាលាបុណ្យផងត្រូវម៉ាច់តែម្តង ស្អែកនេះថ្ងៃភ្ជុំមនុស្សមកច្រើន ត្រូវជួសជុលអោយហើយក្រែងបាក់នាំអោយមានគ្រោះថ្នាក់ !

ប្រធានភូមិ និងតាញ៉ាញ់ ឃើញតាអាចារ្យមកសង្វាតរើសយកដែកគោលល្អៗទុកដូច្នោះ ក៏ស្តីអោយថា ៖

_នែ ! លោកតា ! មកនេះមកយកដែកគោលឬមកជួយដោះស្រាយបញ្ហាគេ ? បើមកសង្វាតយកដែកគោលទេ មិនបាច់ក៏បានដែរ អញ្ជើញទៅវត្តវិញទៅទុកអោយគេធ្វើការតទៅទៀត !។

_អើ !ស្រេចតែពួកឯងយល់ទេ !ខ្ញុំមកនេះគឺមកជួយបំភ្លឺឯងរាល់គ្នា បើអ្នករាល់គ្នាយល់ថាខ្ញុំអត់បានការខ្ញុំទៅវត្តវិញក៏បាន តែមុននិងទៅ ខ្ញុំសុំប្រាប់ពួកឯងទាំងអស់ថារឿងកំណប់របស់លោកថៅកែឈើ ដែលកប់ក្រោយផ្ទះប្អូនញ៉ាញ់នោះមានតែខ្ញុំទេដែលដឹងរឿងពិតប្រាកដ ។ ប៉ុន្តែបើពួកឯងមិនចង់ដឹងទេ ខ្ញុំទៅវិញហើយ.........

លឺវាចាលោកតាអាចារ្យដូច្នោះ ទាំងអស់គ្នាក៏ស្ទុះមកឃាត់លោកតា ។ម្នាក់ៗអង្អែលគាត់ពីមុខពីក្រោយ អញ្ជើញគាត់អោយអង្គុយលើគ្រែ ខ្លះរត់ទៅចាក់ទឹកតែ





មួយពែងមកជូនគាត់ ខ្លះខំយកក្រដាសកាសែតមកខ្ចប់ដែកគោលជូនគាត់ ។លោកតាអាចារ្យអង្គុយស្រួលបួលហើយ លើកពែងតែក្រេបបន្តិចដំណើរបែបយឺតៗតាមទម្លាប់របស់គាត់ ឯអ្នកចោមរោមប្រឹងជជីកសួរគាត់អោយប្រាប់រឿងកំណប់នោះតើវាយ៉ាងណា ទីបំផុតលោកតាក៏ចេញវាចាថា ៖

_រឿងកំណប់នេះមានតែខ្ញុំម្នាក់គត់ដែលដឹងរឿងពិតព្រោះដូចពួកឯងដឹងស្រាប់ហើយ ខ្ញុំរស់នៅភូមិនេះជាង ៥០ឆ្នាំមកហើយ មិនដែលចាកចេញពីភូមិនេះទៅនៅទីណាផ្សេងឡើយ ទោះបីសម័យប៉ុលពតក៏ដោយរឿងអ្វីក្នុងភូមិនេះខ្ញុំដឹងទាំងអស់ ។

ទាក់ទងនិងរឿងកំណប់ថៅកែឈឺនេះ ខ្ញុំសុំប្រាប់ពួកឯងទាំងអស់គ្នាអោយបានដឹងកុំអោយសង្ស័យតទៅទៀតថា ក្រុមគ្រួសារថៅកែឈឺបានត្រូវគេសម្លាប់អស់មួយពូជមែនតែនៅសល់កូនប្រុសម្នាក់ដែរ ដែលរួចផុតពីការកាប់សម្លាប់ ។គឺកូនប្រុសនោះហើយដែលបានមកជីកយកកំណប់នោះបាត់ទៅហើយនៅក្នុងឆ្នាំ ១៩៧៩ ហើយឥឡូវនេះកូនប្រុសថៅកែឈឺនោះ បានទៅរស់នៅស្រុកអាមេរិចឯណោះ ។រឿងនេះកើតឡើងមុនប្អូនញ៉ាញ់ និងកូនស្រីគាត់មករស់នៅភូមិនេះម្ល៉េះបានជាពួកគេមិនដឹង ។ឯកេះគ្រាប់ដែកគោលដែលជីកបាននោះ ជាកំណប់ធម្មតាដែលអ្នកស្រុកអ្នកភូមិកប់ទុក ដូច្នេះហើយបានជាខ្ញុំគិតថាយកដែកគោលនេះទៅប្រើ ជួសជុលគ្រែវត្តទៅកុំអោយវាស័យតទៅទៀត ។

ស្តាប់លឺដូច្នោះហើយទាំងអស់គ្នាក៏ដកដង្ហើមយ៉ាងធូរចេញមក ភាពតានតឹងរឿងកំណប់ទាំងប៉ុន្មានក៏រលាយអស់ទៅ ។ គេគ្រប់គ្នាដឹងច្បាស់ថាលោកតាអាចារ្យមិនដែលនិយាយកុហក់ទេ ។ តាអាចារ្យពោលរួចហើយក៏លើកពែងតែក្រេបបង្ហើយរួចកាន់ដែកគោលដែលពូគ្លីងទើបខ្ចប់អោយមួយកញ្ចប់នោះ ដើរត្រឡប់ទៅវត្តវិញទៅ ។

ក្រោយពេលតាអាចារ្យចេញផុតទៅបរិយាកាស ក៏ចាប់ផ្តើមតានតឹងឡើងវិញ ។នាយតឿដែលទើបមកពីលុបមុខលុបមាត់ស្អាតបាត ត្រូវបានតាញ៉ាញ់ចង្អុលអោយចេញមុខមកដោះស្រាយគ្នា តែនាយតឿអង្គុយបែមុនទៅរកជញ្ជាំងធ្វើព្រងើយ មិនរវីរវល់មកតតាំងអ្វីឡើយ ។ តាញ៉ាញ់តាវ៉ាជាមួយប្រធានភូមិថា ៖

_លោកប្អូនប្រធានភូមិ ! ខ្ញុំមិនសុខចិត្តទេ ! អាល្អិតនោះវាបានចូលក្នុងផ្ទះខ្ញុំចាប់ក្រញឹចមីនាងកូនខ្ញុំនៅក្បែរពាងទឹក ដូចលោកប្អូនឃើញច្បាស់និងភ្នែកវាដូចជាសាហាវខ្លាំងណាស់ មិនអាចអត់អោនអោយបានដាច់ខាត !។

ប្រធានភូមិ ក៏មានសំណូមពរអោយនាយតឿចេញមកបង្ហាញខ្លួន ដើម្បីដោះស្រាយគ្នា នាយតឿក្រាញមិនព្រមចេញមុខមកទេ នាយខ្មៅក៏ទៅក្បែរនាយតឿហើយឱនខ្សិបដាក់នាយតឿថា ៖

_អាតឿ ! ខ្លាចអីអាំ ! ចេញទៅឈរនិយាយជាមួយគេបន្តិចទៅ ! ឯងចាប់កូនក្រមុំគេមែនឬមិនមែន និយាយអោយច្បាស់ទៅ គ្មានអ្នកណាគេយកឯងទៅស្មោរទេ ! នែ៎អានេះអញឃើញកូនតាហ្នុំងស្អាតណាស់ប៉ុឺយ ! សមជាមួយឯងហើយទាបដូចគ្នា ! គួរព្រេងឯងទេដឹង ?

_អញអៀនណាស់ប៉ុឺយអាខ្មៅ ! អញមិនដែលទៅឈរកណ្តាលចំណោមអោយគេមើលមុខដូច្នេះទេ ! ឯងទៅនិយាយជំនួសអញទៅ !(នាយតឿតប)

_យីអាតឿនេះ អញមិនដែលឃើញឯងចេះអៀនម្តងណាសោះ ឥឡូវលោជាឯងចេះអៀនលាក់មុខអី ! អើបើឯងមិនចេញមុខ ទុកអោយអញចេញមុខនិយាយជំនួសក៏បានប៉ុន្តែអញថាអីស្រេចតែអញរ៉ុយ នាយខ្មៅក៏ចាប់និយាយឡើងថា ៖

_ជំរាបលោកមាទាំងអស់គ្នា អាពួកម៉ាកខ្ញុំវាអៀនមិនចេញមុខមកទេ អោយ

ខ្ញុំនិយាយជំនួសវា ប៉ុន្តែដោយភាគីខាងខ្ញុំមានពួក្រឹងពួក្លយនិងរូបខ្ញុំមិនបានឃើញផ្ទាល់ភ្នែកនូវអំពើដែលអាតៀពួកម៉ាកខ្ញុំបានធ្វើចំពោះនាងខាងនោះ ឥឡូវនេះខ្ញុំសុំសាមីខ្លួនជាតួឯកទាំងពីរដែលមានបញ្ហាចូលមកអនុវត្តិឆាកនោះឡើងវិញជាថ្មីម្តងទៀត ដើម្បីងាយនិងពួកយើងវិនិច្ឆ័យតើអាពួកម៉ាកខ្ញុំវាចាប់នាងខាងនោះរបៀបណា ?

តាញាំញ៉ស្តាប់នាយខ្មៅនិយាយប្លុច្នោះក៏ស្រែកឡើងថា ៖

_ស្អី ! អន្ទិតខ្មៅដូចក្អែកឯងចង់មានប្រសាសន៍ថាម៉េច ? ឯងចង់អោយអន្ទិតតៀនោះ ចាប់មីនាងកូនខ្ញុំកណ្តាលចំណោមគេឯងឡើងវិញម្តងទៀត អោយពួកអ្នករាល់គ្នាមើលលេងឬ ? មិនបានទេ !មិនបានជាដាច់អហង្ការ !ហើយម្យ៉ាងទៀតយើងមិនត្រូវការនិយាយជាមួយអន្ទិតខ្មៅឯងទេ យើងត្រូវការនិយាយផ្ទាល់ជាមួយក្មួយតៀ



តែម្តងថាហើយតាញាំញ៉ស្ទុះទៅរកនាយតៀ ហើយទាញដៃនាយតៀចេញពីកៀន
ជញ្ជាំងមក តែត្រូវនាយតៀរើបំរះចេញវិញ នាំអោយមានការប្រទាញប្រទង់គ្នា



ឡើង ។ ទាំងប្រធានភូមិ ទាំងជីវពលចាប់ផ្តើមសម្រួលគូវិវាទហើយនាយតៀក៏ត្រូវបានគេជម្រុញអោយមកឈរទល់មុខនាងញ៉ៅកណ្តាលហ្វូងមនុស្ស ។

ដោយសារពន្លឺអំពូលភ្លើង ៦តឹកចំនួនបីដើមជះពន្លឺភ្លឺដូចថ្ងៃ នាំអោយកម្លោះក្រមុំទាំងពីរឃើញមុខគ្នាបានច្បាស់ចែស ។ នាងញ៉ៅភ្ញាក់ព្រើត ព្រោះនាងមើលឃើញមុខនាយតៀដែលលុបលាងស្អាតបាតក្លាយជាយុវបុរសម្នាក់ស្រស់សង្ហារអស្ចារ្យ ដែលនាងមិនដែលស្រមៃឃើញសោះ នាងគិតក្នុងចិត្តថា ៖

" យី បងតៀនេះស្អាតដូចតួឯកវីដេអូ " ឯនាយតៀវិញខំគយគន់មើលនាងញ៉ៅហើយគិតក្នុងចិត្តដែរថា ៖ "នាងនេះជានារីស្រុកស្រែរមានសម្រស់គួរអោយគយគន់ណាស់, មុនមូលចិញ្ចើមខ្វង់ ទ្រូងព្រហើន តួទងជានារីខ្មែរចំតួ " នាយតៀបើកភ្នែកម្លឹងៗមើលនាងញ៉ៅទាល់តែតាញាំញ៉ស្រែកថា ៖

_ខ្ញី ! ថយចេញបន្តិចកុំចូលជិតវាពេក ប្រយ័ត្នវាចាប់ទៀត !។

នាងញ៉ៅតបទៅឪពុកវិញថា ៖

_បើមិនអោយគេចាប់ម្តងទៀត ធ្វើម៉េចឃើញជាក់ស្តែងពុក ?

_យី ! កូននេះពិចអញត្បុកឥឡូវ ! ចង់អោយគេចាប់អីចង់ម្ល៉េះៗ ថយទៅនៅពីក្រោយអញអោយឆាប់ ! បើវាចង់ចាប់អោយវាចាប់អញជំនួសឯងក៏បានដែរ ! (តាញាំញ៉គំរាមកូន ហើយទាញនាងញ៉ៅចេញពីមុខនាយតៀ ) ពេលនោះអ្នកទាំងអស់គ្នាដែលឈរជុំវិញក៏ចាប់ធ្វើអន្តរាគមឡើង ពួក្លយនិយាយមុនគេថា ៖

_លោកបងញាំញ៉អើយ ! ខ្ញុំសុំអធ្យាស្រ័យម្តងទៅចុះ ! ខ្ញុំក៏ជាអ្នកស្រុកអ្នកភូមិជិតខាងលោកបងដែរ រឿងហេតុដែលកើតឡើងនេះ សុទ្ធតែជាការយល់ច្រឡំទាំងអស់គ្នាទេ ។ ដូចលោកបងជ្រាបស្រាប់ហើយ ក្មួយខ្ញុំខាងនេះសុទ្ធតែមកពីភ្នំពេញទឹក

ថាមកជីកកំណាប់ ពុំមែនបំណងនិងមកចូលផ្ទះលោកបង ចាប់កូនស្រីលោកបងទេ តែឥឡូវនេះកំណាប់ក៏ជីកពុំបាន ហើយកើតមានបញ្ហាប៉ះពាល់ដល់កូនស្រីលោកបងទៀតដូច្នេះពួកយើងសូមទោសលោកបង សូមលោកបងកុំប្រកែប្រកាន់តទៅទៀត ។

អ្នកឯទៀតទាំងជីវពលទាំងតាក្លឹង នាំគ្នានិយាយមួយមាត់ពីរមាត់ម្នាក់អង្វរករតាញាញ់អោយឈប់ប្រកែប្រកាន់ទីបំផុតប្រធានភូមិក៏ងើបឡើងបូកសរុបនិងអារកាត់បញ្ចប់រឿងរ៉ាវ ។

-សូមមេត្តាស្ងាត់ៗ !! សូមស្តាប់ខ្ញុំអ្នកទាំងអស់គ្នាដើម្បីកុំអោយរឿងនេះវែងឆ្ងាយតទៅទៀត ខ្ញុំសូមអាកាត់បញ្ហានេះជូនតែម្តងទៅ ! ទី១រឿងកំណាប់មាសក្លាយជាដែកគោលនេះខ្ញុំសុំស្នើរយកវត្ថុតាងទាំងអស់ដែលមានកេះគ្រាប់និងដែកគោលទាំងមូលប្រគល់ជូនតាញាញ់ជាម្ចាស់ដីភូមិ ព្រោះកំណាប់ដែកគោលនេះជីកបាននៅក្នុងដីភូមិជាកម្មសិទ្ធរបស់គាត់ ។ ទីពីរ រឿងលោកក្មួយតៀបានចូលទៅចាប់កូនស្រីរបស់លោកបងញាញ់នៅក្នុងបន្ទប់ទឹក ក្នុងផ្ទះលោកបងទោះបីជាអំពើនេះកើតឡើងដោយអចេតនាក្តី ក៏ចាត់ថាជាបទល្មើសបំពានលើរូបរាងកាយ រវាងបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀត ច្បាប់ត្រូវតែវិនិច្ឆ័យទោសទៅតាមករិតធ្ងន់ស្រាល ប៉ុន្តែ ! យោលទៅលើសាមីខ្លួនអ្នករងគ្រោះគឺក្មួយស្រីញ៉ី នាងចង់ប្តឹងក្មួយប្រុសតៀដែរឬទេ ? សូមក្មួយស្រីមេត្តាឆ្លើយមួយម៉ាត់យ៉ាងខ្លី ពូនិងសំរេចតាម ក្មួយស្រីភ្លាម !

ប្រធានភូមិសួរទៅនាងញ៉ី ឯនាងញ៉ីធ្វើមឹងមាំងមិនដឹងត្រូវឆ្លើយតបប្រធានភូមិថាម៉េច ឆ្លៀតពេលនោះតាញាញ់ខ្សិបដាក់កូនស្រីថា ៖

-ប្តឹងវាភ្លាមទៅកូន ! ថាអាល្អិតនោះវាចាប់អោបកូនវាច្របាច់កកូនវាស្អីៗ... ចេះតែថាទៅណា៎ ទារជម្ងឺចិត្តវាអោយច្រើនៗមក !



-ដឹងស្អីទេពុកនេះ !ខ្ញុំខ្មាសគេណាស់ថាគេចាប់អោប ថាគេច្របាច់កម៉េចទេ ! ខ្ញុំអត់ថាតាមពុកឯងទេ !

នាងញ៉ីសម្លឹងមើលមុខនាយតៀ នាងនឹកអាណិតខ្លាំងណាស់ព្រោះនាយតៀធ្វើមុខស្រងូតនាងក៏នៅស្ងៀមមិនឆ្លើយតបប្រធានភូមិវិញទេ ប្រធានភូមិក៏សួរបញ្ជាក់នាងថា ៖

-ឥឡូវបើក្មួយស្រីសុខចិត្តលើកលែងការចោទប្រកាន់ក្មួយតៀ ក្មួយស្រីគ្រាន់តែងក់ក្បាលជាសញ្ញាក៏បានដែរ !

នាងញ៉ីក៏ងក់ក្បាលជាសញ្ញាថានាងមិនប្រកាន់និងប្តឹងនាយតៀទេ ។ ទាំងអស់គ្នាចាប់ផ្តើមហើរសប្បាយរីករាយនិងទះដៃអបអរសាទរ នាយខ្មៅលោតសប្បាយជាងគេទៅត្បូកក្បាលនាយតៀមួយក្រញ៉ៃហើយថា ៖"អញជួយអរឯង !"។

តាញាញ់កប់យោបស់មិនដឹងនិយាយថាម៉េច ក៏ទៅអង្គុយចាក់ទឹកតែផឹកម្នាក់ឯងទៅ ។

ក្រោយពេលព្យុះភ្លៀង មេឃក៏ស្រឡះ.ប្រធានភូមិក៏ចាត់ចែងរៀបចំអោយមានបរិយាកាសរីករាយជាមិត្តភាពស្និទ្ធស្នាលឡើងវិញ ដោយគាត់ម្ចីម្នាស្រែកហៅប្រពន្ធនិងកូនគាត់អោយយកនំអន្សមនំគមដែលទើបស្ងោរឆ្អិនថ្មីៗ មួយកញ្ច្រែងមក ។ រួចហើយទាំងភ្ញៀវភ្នំពេញ ទាំងភ្ញៀវក្នុងភូមិចាប់ផ្តើមបរិភោគរួមគ្នាបំភ្លេចរឿងខុសឆ្គងដែលទើបកន្លងទៅ ។

ក្រោយពេលបរិភោគនំនែករួចហើយ តាញាញ់បាននាំកូនស្រីត្រឡប់ទៅផ្ទះគាត់វិញ ឯអ្នកជីកកំណាប់ទាំង ៤នាក់ បានត្រូវប្រធានភូមិឃាត់អោយនៅសំណាក់ផ្ទះគាត់មួយយប់ ស្អែកឡើងទើបពួកនាយខ្មៅ និងនាយតៀវិលត្រឡប់ទៅភ្នំពេញវិញ ។

..............................

តាំងពីថ្ងៃនោះមក នាយតៀមានអារម្មណ៍នឹកមមៃជានិច្ចដល់នាងញ៉ា ហើយនាយចេះតែបបួលនាយខ្មៅធ្វើដំណើរទៅកំពង់ស្ពឺ ទៅលេងផ្ទះតាញាំញ៉ ។ ទៅម្ដងៗនាយតែងកាន់យួររបស់របរចំណីចំណុកផ្សេងៗទៅជូនតាញាំញ៉ និងកូនស្រីគាត់ ។ធ្វើអោយតាញាំញ៉ពេញចិត្តនាយតៀយ៉ាងខ្លាំង ដល់យូរៗទៅក៏ក្លាយជាទម្លាប់ ជួនកាលនាយខ្មៅមិនបានជូនទៅ នាយតៀទៅម្នាក់ឯងសំណាក់នៅផ្ទះតាញាំញ៉ពីរបីយប់ក៏មាន ។ តាញាំញ៉ស្រឡាញ់នាយតៀដូចកូនគាត់ដែរ ព្រោះនាយតៀយល់អធ្យាស្រ័យតាផ្គត់ផ្គង់តាមិនអោយតាខ្វះអ្វីទេ ។

តាមពិតទៅ នាយតៀជាកូនចៅអ្នកមានទ្រព្យធនគ្រាន់បើម្នាក់ នៅភ្នំពេញ ។ ឪពុកនាយតៀជាសមាជិកក្រុមហ៊ុនខាងឧស្សាហកម្មថ្នាំជក់មួយយ៉ាងធំ។នាយតៀមានបងប្អូនបង្កើតប្រាំនាក់ តែជាកូនទីបួនហើយរពិលរពួចជាងគេ រៀនចប់មធ្យមសិក្សាមធ្យមភូមិហើយក៏បែកគំនិតខាងដើរលេងសេចផឹកស៊ីស្រីញីរាំរែក ចូលរួមបក្សពួកជាមួយនាយរាមនាយខ្មៅម៉ូដែលនិងម៉ូដែន ។ប៉ុន្តែនៅពេលដែលនាយរាមត្រូវបានឪពុកមាមកពីស្រុកបារាំងធានាយកទៅរៀននៅប្រទេសបារាំងបាត់ទៅ បក្ខពួករបស់គេដែលនៅសល់ក៏បែកខ្ញែកគ្នាអស់ដែរ ។ នាយតៀបានចូលធ្វើការក្នុងក្រុមហ៊ុនមួយ ជាមួយនាយខ្មៅ ហើយបានសុំអោយ ឪពុកម្ដាយចូលស្ដីដណ្ដឹងនាងញ៉ា ជាភរិយា ពិធីមង្គលការមួយយ៉ាងអធិកអធម បានប្រព្រឹត្តទៅនៅក្នុងភូមិក្បែរមាត់ស្ទឹង ដែលជាទីកកើតអនុស្សាវរីយ៍កំណាប់មាស ក្លាយជាកំណាប់ស្នេហ៍ នៃកម្លោះភ្នំពេញក្រមុំស្រុកស្រែនេះ ។

HUN SEN LIBRARY
R.U.P.P.
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

ចប់